រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

# កម្មវិធីជាតិ
# កំណែទម្រង់រដ្ឋបាលសាធារណៈ
# ២០១៩-២០៣០

សេចក្តីព្រាងលើកទី១

ខែសីហា ឆ្នាំ២០១៩

# មាតិកា


ជំពូកទី១៖សេចក្តីផ្តើម ........ ១

១.១. បរិបទនៃការកែទម្រង់ ........ ១

១.៣. គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីជាតិ ........ ៣

១.៤. អភិក្រមនៃការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ........ ៤

១.៥. រចនាសម្ព័ន្ធឯកសារកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ ........ ៦

ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ........ ៧

២.១. ចក្ខុវិស័យ ........ ៧

២.២. គោលបំណង ........ ៨

២.៣. គោលដៅ ........ ៨

២.៤. យុទ្ធសាស្ត្រ ........ ៩

២.៥. ផែនការសកម្មភាព ២០១៩-២០៣០ ........ ៩

២.៥.១. ដំណាក់កាលទី១(២០១៩-២០២៣)៖ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ........ ១០

២.៥.២. ដំណាក់កាលទី២(២០២៣-២០២៧)៖ ការអនុវត្តនិងការត្រួតពិនិត្យ វាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ........ ១២

២.៥.៣. ដំណាក់កាលទី៣(២០២៧-២០៣០)៖ គណនេយ្យភាពសមិទ្ធកម្ម ចំពោះសេវាសាធារណៈ ........ ១៣

ជំពូកទី៣៖ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ........ ១៤

៣.១. ដំណាក់កាលនៃការអនុវត្តកម្មវិធីជាតិ ........ ១៤

៣.២. យន្តការស្ថាប័នសម្រាប់ការអនុវត្តកម្មវិធីជាតិ ........ ១៤

ជំពូកទី៤៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ ........ ១៧

៤.១. សូចនាករគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ........ ១៧

៤.២. ប្រព័ន្ធរបាយការណ៍ ........ ១៨

៤.៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ........ ១៨

ជំពូកទី៥៖ ប្រភពធនធាននិងគោលការណ៍លើកទឹកចិត្តដែលគាំទ្រដល់ ការរៀបចំនិងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ........ ២០

ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន ........ ២១

ឧបសម្ព័ន្ធ ១៖ សាវតានិងសមិទ្ធផលសង្ខេបនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់ រដ្ឋបាលសាធារណៈ ........ ២៣

ឧបសម្ព័ន្ធ២៖ តារាងផែនការសកម្មភាព-កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល២០១៩-២០៣០ ........ ២៧

# ជំពូកទី១៖សេចក្តីផ្តើម

## ១.១. បរិបទនៃការកែទម្រង់

នៅក្នុងនិន្នាការសកលសម្រាប់រដ្ឋាភិបាលនីមួយៗ គឺត្រូវបន្តការកែលម្អការផ្តល់សេវាសាធារណៈឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានប្តេជ្ញាចិត្តយ៉ាងមុតមាំនៅក្នុងការពង្រឹងរដ្ឋបាលសាធារណៈផងដែរ តាមរយៈការដាក់ចេញនូវការកែទម្រង់រដ្ឋបាលសាធារណៈជា៥ដំណាក់កាលដែលគិតចាប់តាំងពីឆ្នាំ១៩៩៣[1] មកម្លេះ ហើយការអនុវត្តការកែទម្រង់នេះសម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់។ ក្នុងបរិការនេះ រាជរដ្ឋាភិបាល បានដាក់ចេញនូវដំណាក់កាលថ្មីក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ដោយបានកំណត់ថា គុណភាពនៃការដឹកនាំស្ថាប័ននិងការរីកចម្រើននៃសេដ្ឋកិច្ច គឺមានលក្ខណៈផ្សារភ្ជាប់គ្នា ហើយចំណុចនេះជាគោលបំណងនៃកំណែទម្រង់អភិបាលកិច្ចដែលជាចំនុចស្នូលនៃយុទ្ធសាស្ត្រចតុកោណ។

រាជរដ្ឋាភិបាលកម្ពុជា បានបន្តជំរុញការអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ដែលជាកិច្ចការយ៉ាងសំខាន់ដើម្បីសម្រេចបាននូវគោលបំណងរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជា ប្រទេសមួយដែលមានចំណូលខ្ពស់និងមានស្តង់ដារស់នៅល្អ។ ក្នុងន័យនេះ ការកើនឡើងនូវប្រាក់ចំណូលការធ្វើនគូបនីយកម្ម និងការធ្វើសមាហរណកម្មកាន់ តែច្រើនឡើង ជាមួយពិភពលោកពាក់ព័ន្ធនឹងសេដ្ឋកិច្ចនិងវប្បធម៌ នឹងនាំឱ្យមានការផ្លាស់ប្តូរនូវការរំពឹង ទុកជុំវិញប្រសិទ្ធភាពនៃការអនុវត្តការងាររបស់មន្ត្រីរាជការ ក្នុងការឈានទៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ហើយចំនុចទាំងនេះ គឺជាបញ្ហាមួយដែលរាជរដ្ឋាភិបាលត្រូវដោះស្រាយដើម្បីធ្វើឱ្យសម្រេចបាននូវការរំពឹង ដូចបានបង្ហាញ។

ក្រៅពីបញ្ហាប្រឈមទាំងនេះ គឺនៅមានបញ្ហាច្រើនទៀតដែលត្រូវដោះស្រាយ បើទោះបីជាការអនុវត្តកន្លងមកសម្រេចបានលទ្ធផលជាច្រើនក្នុងផ្នែកខ្លះក៏ដោយ មានដូចជា ការលើកកម្ពស់ការផ្តល់សេវាសាធារណៈជួរមុខនៅក្នុងវិស័យសុខាភិបាល និងអប់រំ ការដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ ដែលមានសារៈសំខាន់និងជាលទ្ធផលមានប្រជាប្រិយភាពសម្រាប់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៥-២០១៨។ ការដំឡើងប្រាក់បៀវត្សមន្ត្រីរាជការ បានធ្វើឱ្យមានការទាក់ទាញចូលបម្រើ ការងារក្នុងវិស័យសាធារណៈដែលធ្វើឱ្យចំនួនមន្ត្រីរាជការកាន់តែច្រើនឡើង។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានិរន្តរភាពហិរញ្ញវត្ថុរយៈពេលវែង ទំហំមន្ត្រីរាជការ ផលិតភាពការងារ ប្រាក់បៀវត្ស ផ្អែកលើសមិទ្ធកម្ម និងលទ្ធភាពទ្រទ្រង់បានសម្រាប់មន្ត្រីដែលមានសមត្ថភាព ជាពិសេស ចំពោះបុគ្គលមានសមត្ថភាពខ្ពស់ ដែលត្រូវបានជ្រើសរើសនិងរក្សាទុក ក៏នៅតែចោទជាបញ្ហា។

សរុបមក រាជរដ្ឋាភិបាល រំពឹងទុកថា កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ នឹងមានការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មពេញលេញ ការតាមដានត្រួតពិនិត្យការអនុវត្ត

[1] សាវតានិងសមិទ្ធផលនៃការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ៥ដំណាក់កាលចាប់ពីឆ្នាំ១៩៩៣ មានបញ្ជាក់លំអិតនៅក្នុងឧបសម្ព័ន្ធទី១នៃឯកសារកម្មវិធីជាតិនេះ

និងគណនេយ្យភាពសម្រាប់ឧត្តមភាពនៃការផ្តល់សេវាសាធារណៈ។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនេះ នឹងដាក់ឱ្យអនុវត្តជាពដំណាក់កាល ក្នុងដំណាក់កាលនីមួយៗ ត្រូវកំណត់នូវចង្កោមសកម្មភាពសម្រាប់អនុវត្ត។ សកម្មភាពទាំងនេះ ទាមទារឱ្យមានការកែទម្រង់ស្ថាប័នជាមូលដ្ឋានគ្រឹះ ដើម្បីធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការរបស់រាជរដ្ឋាភិបាល និងសម្របសម្រួលការគ្រប់គ្រងការផ្លាស់ប្តូរ។ សកម្មភាពទាំងនេះ នឹងរួមបញ្ចូលការពិនិត្យឡើងវិញនូវមុខងារដំណើរការនៃការអនុវត្តរបស់អង្គភាព និងក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវាសាធារណៈ ការធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌនៃគ្រប់គ្រងធនធានមនុស្ស និងស្របជាមួយនឹងយុទ្ធសាស្ត្រពាក់ព័ន្ធនានា ការទទួលស្គាល់និងវាយតម្លៃស្តង់ដារសេវាសាធារណៈការប្រើប្រាស់ជាអតិបរមានៃបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ដំណោះស្រាយប្រកបដោយ នវានុវត្តន៍ និងការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការផ្តល់សេវា ប្រកបដោយគុណភាព។ ជារួមចក្ខុវិស័យនៃការកែទម្រង់នេះ នឹងធ្វើឱ្យ*រដ្ឋបាលសាធារណៈ ស្អាតស្អំ វៃឆ្លាត ខ្លាំង និងផ្តោតលើប្រជាជន ជាស្នូល*។

## ១.២. បញ្ហានិងការលទុវត្តភាពរបស់រដ្ឋបាលសាធារណៈ

ការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ ថ្មីនេះឡើង គឺស្ថិតនៅក្នុងបរិយាកាសនៃកំណើនសេដ្ឋកិច្ច និងស្ថេរភាពនយោបាយនៅកម្ពុជា ក៏ដូចជាការប្តេជ្ញាចិត្តខ្ពស់របស់រដ្ឋាភិបាលក្នុងការអនុវត្តការកែទម្រង់មុខងារសាធារណៈ។ ទន្ទឹមនេះ ប្រទេសកម្ពុជា ក៏មានប្រជាជនវ័យក្មេងហើយមានសក្តានុពលខ្ពស់ ដោយបានជ្រើសរើសចេញពីកំលាំងពលកម្មដែលមានការអប់រំសម្រាប់តួនាទីជាមន្ត្រីរាជការ។ ក្រៅពីនេះ ភាពអាចប្រើប្រាស់បាននូវអ៊ីនធើណែត និងស្មាតហ្វូន មានលក្ខណៈទូលំទូលាយ (ស្ទើរតែជាសកល) ហើយប្រជាជនកម្ពុជា ក៏បានស្គាល់នូវបណ្តាញទំនាក់ទំនងសង្គមដែលនេះជាកាលានុវត្តន៍ថ្មីក្នុងការផ្តល់ព័ត៌មានអំពីសេវាកម្មរបស់រាជរដ្ឋាភិបាល។ យ៉ាងណាមិញ បើក្រឡេកទៅមើលអាត្រាអ្នកទៅបោះឆ្នោតមានកំណើនខ្ពស់និងការចូលរួមរបស់ប្រព័ន្ធផ្សព្វផ្សាយសង្គម គឺអាចបង្ហាញពីឆន្ទៈរបស់ប្រជាជនកម្ពុជាក្នុងការចូលរួមដំណើរការកែទម្រង់ដែលនឹងផ្តល់សេវាសាធារណៈឱ្យមានភាពល្អប្រសើរឡើងសម្រាប់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ទោះបីជាមានចំណុចវិជ្ជមានទាំងនេះក្តី ក៏នៅមានបញ្ហាសំខាន់ៗជាច្រើន ក្នុងក្របខណ្ឌមន្ត្រីរាជការកម្ពុជា និងត្រូវដោះស្រាយដូចមានខាងក្រោម៖

### ១. ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស និងប្រាក់បៀវត្ស

គោលបំណងជាយុទ្ធសាស្ត្រដែលជាចំណុចស្នូលនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺការបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដែលនឹងជួយគាំទ្រដល់ការធ្វើទំនើបកម្ម និងផលិតភាពការងារខ្ពស់សម្រាប់មន្ត្រីរាជការ។ ការអនុវត្តជាដំណាក់កាលៗគឺមានលក្ខណៈសំខាន់ដែលជា លក្ខខណ្ឌតម្រូវក្នុងការអនុវត្ត ដោយក្នុងនោះរួមបញ្ចូលផងដែរនូវការរៀបចំបញ្ចប់និងដាក់ឱ្យអនុវត្តការគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា ការពិពណ៌នាមុខតំណែងនិងប្រព័ន្ធចំណាត់ថ្នាក់ ដំណើរការ និងនីតិវិធីនៃការជ្រើសរើសប្រកបដោយគុណាធិបតេយ្យ និងការអភិវឌ្ឍសមត្ថភាពភាពជាអ្នកដឹកនាំ ដោយរួមបញ្ចូលទាំងការគ្រប់គ្រងការផ្លាស់ប្តូរ។

ទន្ទឹមនេះ ក៏នៅមានបញ្ហាពាក់ព័ន្ធនឹងឥរិយាបទមន្ត្រីក្នុងអង្គភាពថាតើអនុវត្តដោយការដាក់ទណ្ឌកម្មចំពោះ មន្ត្រីដែលអនុវត្តការងារមិនទទួលបានលទ្ធផល ឬក៏ផ្តល់រង្វាន់។ បញ្ហាទី២នេះ នឹងនាំឱ្យមានការចោទសួរ ពាក់ព័ន្ធទៅនឹងប្រាក់បៀវត្ស និងរចនាសម្ព័ន្ធនៃបៀវត្ស រួមទាំងការផ្តល់ការលើកទឹកចិត្តជាហិរញ្ញវត្ថុ សម្រាប់ ការបំពេញការងារទទួលបានលទ្ធផលល្អប្រសើរ។

**២. ការកែទម្រង់ការផ្តល់សេវាសាធារណៈ**

បើទោះបីជាការផ្តល់សេវាសាធារណៈបានកែលម្អឱ្យមានភាពប្រសើរឡើងនៅតាមតំបន់ខ្លះជាច្រើន នៅឧទាហរណ៍ ការផ្តល់សេវាតាមច្រកចេញចូលតែមួយ ដែលផ្តល់នូវកាលានុវត្តភាព ធ្វើឱ្យដំណើរការនៃការផ្តល់សេវាមានលក្ខណៈសាមញ្ញ និងធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ក្នុងការផ្តល់ព័ត៌មាននិងសេវាដល់ប្រជាជន និងពេលវេលានៃការផ្តល់សេវាត្រូវបានកាត់បន្ថយ។ ការបន្តយកចិត្តទុកដាក់លើផលិតភាព គឺមានលក្ខណៈសំខាន់ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុករបស់ប្រជាជនកម្ពុជាចំពោះការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។

**៣. កិច្ចសហការ និងការផ្សារភ្ជាប់សកម្មភាពកែទម្រង់របស់រាជរដ្ឋាភិបាល**

ភាពជោគជ័យរបស់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងតម្រូវឱ្យមានការកែលម្អទំនាក់ទំនងស្ថាប័ន និងកិច្ចសហការដោយផ្សារភ្ជាប់នូវសកម្មភាពកំណែទម្រង់របស់រដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព ហើយសកម្មភាពកែទម្រង់នេះ នឹងត្រូវបញ្ចូលទៅក្នុងផែនការសកម្មភាពរបស់ក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រការនេះ នឹងតម្រូវឱ្យមានការផ្លាស់ប្តូរផ្នត់គំនិតនៅកម្រិតមន្ត្រីនីមួយៗ ការពង្រឹងសមត្ថភាពស្ថាប័ន និងការសម្របសម្រួលអន្តរស្ថាប័ន ឆន្ទៈនិងសមត្ថភាពក្នុងការចែករំលែកទិន្នន័យនៅគ្រប់កម្រិត និងការបង្កើតយន្តការត្រួតពិនិត្យ និងវាយតម្លៃ ប្រកបដោយប្រសិទ្ធភាព។ ដូចនេះ រាជរដ្ឋាភិបាលអាចធានាបានថាការអនុវត្តនូវរបៀបវារៈកែទម្រង់ ត្រូវបានចូលរួមអនុវត្តដោយគ្រប់ក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១.៣. គោលនយោបាយ និងក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីជាតិ

នៅក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណទាំង៣(បី)ដំណាក់កាលកន្លងមក រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានវឌ្ឍនភាពជាមូលដ្ឋានក្នុងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈកម្មវិធីជាតិកែទម្រង់ជាច្រើនក្នុងនោះការកែទម្រង់រដ្ឋបាលសាធារណៈបានរួមចំណែកយ៉ាងសំខាន់ក្នុងបេសកកម្មនេះ។ ជាបន្តក្នុងនីតិកាលទី៦នៃរដ្ឋសភា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល បានដាក់ចេញនូវគោលដៅនិងវិធានការណ៍ជាច្រើន ដើម្បីបង្កើនល្បឿនបន្ថែមទៀតសម្រាប់ការកែទម្រង់អភិបាលកិច្ច។

ក្នុងក្របខណ្ឌជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីឆ្លើយតបទៅនឹងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ចក្ខុវិស័យ

របស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៥០ ដោយឆ្លុះបញ្ចាំងទៅនឹងបង្គោលចរឆ្នាំ២០៣០ ក្នុងការប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។

ការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ តម្រូវឱ្យមានការកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងដំណាក់កាលនៃការអនុវត្តសកម្មភាពកែទម្រង់ឱ្យបានច្បាស់លាស់និងប្រាកដនិយម។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ជាឯកសាររស់ដែលអាចត្រូវកែប្រែផ្អែកលើបរិបទសេដ្ឋកិច្ច នយោបាយ និងសង្គមរបស់កម្ពុជា។ កម្មវិធីនេះ នឹងត្រូវរៀបចំនិងដាក់ឱ្យអនុវត្តផ្អែកលើការចូលរួមពិគ្រោះយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ និងភាពប្រទាក់ក្រឡាជាមួយផែនការសកម្មភាពកែទម្រង់របស់ការដ្ឋានកែទម្រង់សំខាន់ៗ រួមមាន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យអាទិភាព ពិសេសវិស័យអប់រំនិងសុខាភិបាល ក្នុងន័យអាចដោះស្រាយបញ្ហាដែលកំពុងជួបប្រទះនាពេលបច្ចុប្បន្ននិងនាពេលអនាគតនិងការកសាងរដ្ឋបាលរឹងមាំ និងប្រកបដោយប្រសិទ្ធភាពស្របតាមបរិបទអន្តរជាតិ។

## ១.៤. អភិក្រមនៃការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងត្រូវរៀបចំផ្អែកលើឯកសារទស្សនទានដែលកំណត់អំពីចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ ក្របខណ្ឌនៃការអនុវត្តជាដំណាក់កាលៗ យន្តការសម្របសម្រួលកម្រិតស្ថាប័ន ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព្រមជាមួយប្រភពធនធាន ដែលគាំទ្រដល់ការរៀបចំ និងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ឯកសារទស្សនទាននេះ ត្រូវបានរៀបចំឡើងដោយផ្អែកទៅលើការត្រួតពិនិត្យឡើងវិញនូវ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល-សាធារណៈកន្លងមក ឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល ធាតុចូលពីការពិគ្រោះយោបល់រវាងដៃគូអភិវឌ្ឍ និងដៃគូពាក់ព័ន្ធនានា។ ទន្ទឹមនេះ ឯកសារទស្សនទាន ត្រូវបានដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ និងទទួលបានការឯកភាពពីលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មុនពេលដាក់ស្នើសុំគោលការណ៍ឯកភាពពីសម្តេចតេជោនាយករដ្ឋមន្ត្រី។

បន្ទាប់ពីទទួលបានការពិនិត្យសម្រេច និងមតិដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រីលើឯកសារទស្សនទាននេះ (លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រីចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩) ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នឹងចាប់ផ្តើមអនុវត្តការងារសម្រាប់ការរៀបចំ និងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ តាមជំហានការងារដូចខាងក្រោម៖

| ការរៀបចំនិងអនុវត្តកម្មវិធីជាតិ | | | |
|---|---|---|---|
| ជំហានទី១៖ ការរៀបចំសេចក្ដីព្រាង | ជំហានទី២៖ ការពិគ្រោះយោបល់ | ជំហានទី៣៖ ការអនុម័តកម្មវិធីជាតិ | ជំហានទី៤៖ ការអនុវត្តកម្មវិធីជាតិ |

## ជំហានទី១៖ ការរៀបចំសេចក្ដីព្រាង

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈនិងក្រុមការងារបច្ចេកទេសកែទម្រង់រដ្ឋបាលសាធារណៈរបស់ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំសិក្សា ស្រាវជ្រាវ ចងក្រង និងប្រមូលធាតុចូលពាក់ព័ន្ធនឹងក្របខណ្ឌ ចក្ខុវិស័យ យុទ្ធសាស្ត្រ កម្មវិធីជាតិ កម្មវិធីកែទម្រង់និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងចំណេះដឹងបទពិសោធន៍ពីអ្នកជំនាញជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍនានា ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំឯកសារសេចក្ដីព្រាងកម្មវិធីជាតិ។

## ជំហានទី២៖ ការពិគ្រោះយោបល់

គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ នឹងដាក់សេចក្ដីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យមានការផ្ដល់យោបល់ពីភាគីពាក់ព័ន្ធ តាមរយៈសិក្ខាសាលា កិច្ចប្រជុំចង្អៀតអន្តរក្រសួងកម្រិតបច្ចេកទេស និងកិច្ចប្រជុំអន្តរក្រសួងបើកទូលាយ ពិសេសជាមួយលេខាធិការដ្ឋាន និងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់របស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិរដ្ឋបាល ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ សាកលវិទ្យាល័យ ព្រមទាំងដៃគូពាក់ព័ន្ធដទៃទៀត។

## ជំហានទី៣៖ ការអនុម័តកម្មវិធីជាតិ

សេចក្ដីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងត្រូវដាក់ឆ្លងកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យនិងផ្ដល់យោបល់ចុងក្រោយ។ បន្ទាប់មកសេចក្ដីព្រាងកម្មវិធីជាតិនេះ គ្រោងនឹងដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅត្រីមាសទី៣ ឆ្នាំ២០១៩ ដើម្បីពិនិត្យនិងអនុម័ត។

## ជំហានទី៤៖ ការអនុវត្តកម្មវិធីជាតិ

ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បំពេញតួនាទីជាស្ថាប័នដឹកនាំ សម្របសម្រួល ជំរុញការអនុវត្ត និងផ្ដល់ជំនួយផ្នែកបច្ចេកទេសនៅក្នុងការអនុវត្តកម្មវិធី

ជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ រួមបញ្ចូលទាំងការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ ព្រមទាំងរាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិជូនប្រមុខរាជរដ្ឋាភិបាលកម្ពុជា។

ដោយឡែកក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានការកិច្ចរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈដែលបានកំណត់នៅក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដោយយកផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈនេះទៅដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ១.៥. រចនាសម្ព័ន្ធឯកសារកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០

ឯកសារកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០៖ ត្រូវបានរៀបចំឡើងជា ៦ជំពូក និងមានភ្ជាប់ឧបសម្ព័ន្ធ ដូចខាងក្រោម៖

- ជំពូកទី១៖ សេចក្តីផ្តើម-បរិបទនៃកំណែទម្រង់ បញ្ហានិងកាលានុវត្តភាពរបស់រដ្ឋបាលសាធារណៈ គោលនយោបាយនិងក្របខណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីជាតិ អភិក្រមនៃការរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងរចនាសម្ព័ន្ធឯកសារកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០
- ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០-ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ ផែនការសកម្មភាព ២០១៩-២០៣០
- ជំពូកទី៣៖ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ - ដំណាក់កាលនៃការអនុវត្តកម្មវិធីជាតិ យន្តការស្ថាប័ន
- ជំពូកទី៤៖ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិ ក្នុងនោះផ្តោតលើសូចនាករគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ប្រព័ន្ធរបាយការណ៍ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ
- ជំពូកទី៥៖ ប្រភពធនធាននិងគោលការណ៍លើកទឹកចិត្តដែលគាំទ្រដល់ការរៀបចំនិងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន
- ឧបសម្ព័ន្ធ១៖ សាវតានិងសមិទ្ធផលសង្ខេបនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ឧបសម្ព័ន្ធ២៖ តារាងផែនការសកម្មភាព-កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

# ជំពូកទី២៖ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

## ២.១. ចក្ខុវិស័យ

ចក្ខុវិស័យកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ គឺដើម្បីធានាឱ្យបាននូវ **រដ្ឋបាលសាធារណៈ ស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្តោតលើប្រជាជនជាស្នូល** សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន សមធម៌ និង យុត្តិធម៌។




រដ្ឋបាលសាធារណៈ នឹងដំណើរការឈរលើគុណតម្លៃដូចខាងក្រោម៖

- **ស្អាតស្អំ៖** មន្ត្រីកាន់សុចរិតធម៌ បំពេញការងារប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវ ឈរលើអភិក្រម ***ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់***
- **ឆ្លាតវៃ៖** រដ្ឋបាលប្រើប្រាស់នវានុវត្តន៍ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យា និងបច្ចេកវិទ្យាទាន់សម័យក្នុងការផ្តល់សេវាឱ្យមានប្រសិទ្ធភាពនិងប្រសើរជាលំដាប់ ព្រមទាំងចូលរួមសម្រាប់តម្រូវការនាពេលអនាគត
- **ខ្លាំង៖** រដ្ឋបាលមានសមត្ថភាពរឹងមាំ នវានុវត្តន៍ ដំណើរការ និងអាចបត់បែនឆ្លើយតបទៅនឹងបរិបទសង្គមប្រកបដោយនិរន្តភាពនិងប្រសិទ្ធភាព

- **ប្រជាជនជាស្នូល៖** រដ្ឋបាលដាក់ប្រជាជនជាស្នូលនៃការផ្តល់សេវាសាធារណៈ និងឈរលើព្រហ្មវិហារធម៌ដោយមានការចូលរួមពីប្រជាជនក្នុងដំណាក់កាលនៃការរៀបចំការអភិវឌ្ឍ ការផ្តល់និងការត្រួតពិនិត្យនិងវាយតម្លៃសេវា។

## ២.២. គោលបំណង

គោលបំណងជាយុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺដើម្បីធានាឱ្យបាននូវ**ការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព** សំដៅគាំទ្រដល់ការសម្រេចចក្ខុវិស័យនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។

## ២.៣. គោលដៅ

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងដាក់ចេញនូវគោលដៅជាក់លាក់ដែលត្រូវអនុវត្តនិងធ្វើឱ្យសម្រេចបានជាដំណាក់កាលៗ ដូចខាងក្រោម៖

ដំណាក់កាលទី១ (២០១៩-២០២៣) ៖ ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

ដំណាក់កាលទី២ (២០២៣-២០២៧)៖ ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

ដំណាក់កាលទី៣ (២០២៧-២០៣០) ៖ គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ

សកម្មភាពគោលកែទម្រង់ពាក់ព័ន្ធនឹងការកែទម្រង់ និងការលើកកម្ពស់សមត្ថភាពស្ថាប័ន ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ និងការពង្រឹងប្រសិទ្ធភាពអនុវត្តការងារ នឹងត្រូវកំណត់ក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈចាប់ពីដំណាក់កាលទី១ ដើម្បីសម្រេចឱ្យបានជោគជ័យជាបន្តបន្ទាប់នូវគោលបំណងនៃការកសាងប្រព័ន្ធគ្រប់គ្រងដោយផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

### កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០

**គោលបំណង៖ ការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈប្រកបដោយប្រសិទ្ធភាព**

**គោលដៅ៖ អនុវត្តជា៣ដំណាក់កាលៗ**

| ដំណាក់កាលទី១<br>២០១៩-២០២៣ | ដំណាក់កាលទី២<br>២០២៣-២០២៧ | ដំណាក់កាលទី៣<br>២០២៧-២០៣០ |
|---|---|---|
| • ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | • ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ | • គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ |

**យុទ្ធសាស្ត្រ**

1. ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ
2. ការជំរុញនិងការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
3. ការផ្សារភ្ជាប់សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈជាមួយការដ្ឋានកែទម្រង់របស់រាជរដ្ឋាភិបាល

## ២.៤. យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យនៃកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺ **រដ្ឋបាលសាធារណៈស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្តោតលើប្រជាជនជាស្នូល** យុទ្ធសាស្ត្រចំបងចំនួន៣ត្រូវបានដាក់ចេញ៖

**(១).ការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ** ត្រូវ៖

- ជំរុញរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់ការបង្កើតសេដ្ឋកិច្ចឌីជីថលនិងការអនុវត្តរដ្ឋបាលឌីជីថល
- ប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីទទួលយកយោបល់ត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ ពង្រឹងការចែករំលែកព័ត៌មាននៅរដ្ឋបាលសាធារណៈគ្រប់កម្រិត
- ពង្រឹងនិងពង្រីកការធ្វើបច្ចុប្បន្នភាពព័ត៌មានសេវាសាធារណៈ
- ពង្រឹងការគ្រប់គ្រងទិន្នន័យនិងព័ត៌មានមន្ត្រីរាជការ
- ជំរុញនិងលើកទឹកចិត្តឱ្យមានការច្នៃប្រឌិតក្នុងការផ្តល់សេវាសាធារណៈ។

**(២).ការជំរុញនិងការរៀបចំដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រង ផ្អែកលើសមិទ្ធកម្ម ត្រូវ៖**

- បង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- រៀបចំនិងប្រើប្រាស់សូចនាករគោលសម្រាប់ការផ្តល់សេវាសាធារណៈនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- សាកល្បងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- បង្កើតយន្តការត្រួតពិនិត្យនិងវាយតម្លៃ។

**(៣).ការផ្សារភ្ជាប់សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈជាមួយនឹងការកែទម្រង់ទាំងឡាយរបស់រាជរដ្ឋាភិបាល** រួមមាន៖ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងគោលនយោបាយតាមវិស័យ ពិសេសអប់រំនិងសុខាភិបាល។ ក្នុងយុទ្ធសាស្ត្រនេះ ត្រូវផ្តោតលើ៖

- កម្មវិធីថវិកានិងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម
- ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនិងការផ្ទេរមុខងារនិងធនធាន
- ការរួមបញ្ចូលសេវាសាធារណៈឱ្យមានលក្ខណៈជាប្រព័ន្ធ
- ការផ្សារភ្ជាប់សកម្មភាពកែទម្រង់និងគោលនយោបាយ
- ការពង្រឹងយន្តការសម្របសម្រួលស្ថាប័ន
- ភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងការផ្លាស់ប្តូរ។

## ២.៥. ផែនការសកម្មភាព ២០១៩-២០៣០

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងត្រូវរៀបចំដាក់ឱ្យអនុវត្តជាដំណាក់កាលៗ ដោយឈរលើមូលដ្ឋានចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល សមត្ថភាពនិងលទ្ធភាពនៃការអនុវត្តរបស់កម្ពុជា និងបទពិសោធន៍អន្តរជាតិក្នុងក្របខណ្ឌនៃការអភិវឌ្ឍ

និងការវិវត្តន៍នៃរដ្ឋបាលសាធារណៈ។ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ នឹងត្រូវរៀបចំដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៩-២០៣០ ដែលនឹងដាក់ចេញនិងអនុវត្តនូវសកម្មភាពជាដំណាក់កាលៗក្នុងនោះ៖

### ២.៥.១. ដំណាក់កាលទី១(២០១៩-២០២៣)៖ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈដំណាក់កាលទី១ នឹងត្រូវអនុវត្តចាប់ពីឆ្នាំ ២០១៩-២០២៣ ដើម្បីសម្រេចគោលដៅនៃការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ ការកសាងមូលដ្ឋាននៃការវាយតម្លៃសមិទ្ធកម្ម ព្រមទាំងសម្រាប់ការសម្រេចគោលដៅក្នុងដំណាក់កាលបន្តបន្ទាប់។

**ចង្កោមសកម្មភាព១៖ កែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ**

សកម្មភាព ១.១ ធ្វើវិភាគមុខងារ ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ននិង ការសម្របសម្រួលអន្តរស្ថាប័ន ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួង ស្ថាប័ននីមួយៗ

សកម្មភាព ១.២ ពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងសាមគ្គីភាពផ្ទៃក្នុងស្ថាប័ន ការរៀបចំនិងអនុវត្តហ្វឹកហ្វឺននូវក្រុមប្រតិបត្តិសម្រាប់បំពេញការងារ និងការសម្រិតសម្រាំងកមន្ត្រីមានសមត្ថភាពខ្ពស់និងគុណវុឌ្ឍិល្អប្រសើរសម្រាប់ការតែងតាំងមុខតំណែងដឹកនាំក្នុងរដ្ឋបាលសាធារណៈព្រមទាំងការលើកកម្ពស់សមត្ថភាព និងតួនាទីរបស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ

សកម្មភាព ១.៣ លើកកម្ពស់គុណាធិបតេយ្យក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈ និងអង្គភាពសាធារណៈ ជាពិសេសការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មក្នុងវិស័យសាធារណៈ

សកម្មភាព ១.៤ ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈការរៀបចំលិខិតបទដ្ឋានហេដ្ឋារចនាសម្ព័ន្ធការងារ ក្របខណ្ឌអភិវឌ្ឍមូលធនមនុស្សដែលទាក់ទាញសមត្ថភាពជំនាញនិងទេពកោសល្យ និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាន និងទិន្នន័យសាធារណៈ

**ចង្កោមសកម្មភាព ២៖ ពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ**

សកម្មភាព ២.១ ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីសេវាសាធារណៈ និងពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកប្រើប្រាស់សេវាសាធារណៈ

សកម្មភាព ២.២ កែលម្អនីតិវិធីនិងកាត់បន្ថយរយៈពេលនៃការផ្តល់សេវាសាធារណៈ

សកម្មភាព ២.៣ ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ចនិងសវនកម្មក្នុងវិស័យសាធារណៈ

សកម្មភាព ២.៤ ពង្រឹងប្រសិទ្ធភាពរៀបចំនិងអនុវត្តក្រមសីលធម៌ការងារ ព្រមទាំងគោលការណ៍វិសមតភាពមុខងារ និងទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ

សកម្មភាព ២.៥ ជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា រួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីគាំទ្រការអនុវត្ត

**ចង្កោមសកម្មភាព ៣៖ ពង្រឹងប្រសិទ្ធភាពការងារនៃការអនុវត្តការងារ**

សកម្មភាព ៣.១ បន្តដំឡើងបៀវត្សជារៀងរាល់ឆ្នាំជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទព្រមទាំងប្រាក់សោធនជូននិវត្តន៍ជននិងអតីតយុទ្ធជនដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារក្នុងរយៈពេលពីរសប្តាហ៍ម្តង

សកម្មភាព ៣.២ ធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងចែករំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការដល់អង្គភាពរដ្ឋបាលគ្រប់កម្រិតក្រោមឱវាទក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបានស្វ័យភាពសមស្របទាំងក្នុងការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្សនិងហិរញ្ញវត្ថុទន្ទឹមនឹងការកំណត់ឱ្យបានច្បាស់លាស់នូវគណនេយ្យភាព និងការទទួលខុសត្រូវរបស់អង្គភាពសាធារណៈនិងមន្ត្រីសាធារណៈ

សកម្មភាព ៣.៣ ជំរុញនវានុវត្តន៍និងរដ្ឋបាលឯកភាពក្នុងកម្រិតក្រុង ស្រុក ខណ្ឌ ខេត្ត រាជធានី ដើម្បីធានាប្រសិទ្ធភាពទាំងក្នុងការបំពេញមុខងារ និងទាំងក្នុងការប្រើប្រាស់ធនធាន

សកម្មភាព ៣.៤ ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំនិងគ្រប់គ្រងស្ថាប័នសាធារណៈ

សកម្មភាព ៣.៥ ដាក់ឱ្យអនុវត្តយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ដើម្បីជំរុញការអនុវត្តកែលម្អវិធានការតម្រង់ទិស យុទ្ធសាស្ត្រ និងពង្រឹងកិច្ច

សហប្រតិបត្តិការអន្តរក្រសួងសម្រាប់ការកសាង រៀបចំ និងអនុវត្ត គោលនយោបាយរបស់រាជរដ្ឋាភិបាល

សកម្មភាព ៣.៦ ពង្រឹងយន្តការចែករំលែកនិងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈ នៅគ្រប់កម្រិតនៅទូទាំងប្រទេស ដើម្បីលើកកម្ពស់ប្រសិទ្ធភាព នៃការគ្រប់គ្រងនិងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងការវិវត្តដ៏ឆាប់រហ័សនៃបរិការណ៍ជាតិនិងអន្តរជាតិ

## ២.៥.២. ដំណាក់កាលទី២(២០២៣-២០២៧)៖ ការអនុវត្តនិងការត្រួតពិនិត្យវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ

បន្ទាប់ពីការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តសកម្មភាពកែទម្រង់ដំណាក់កាលទី១ សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដំណាក់កាលទី២ នឹងត្រូវអនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧ ដើម្បីសម្រេចគោលដៅនៃការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈរួមជាមួយនឹងការដាក់ចេញនូវយន្តការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធនេះ។

**ចង្កោមសកម្មភាព ១៖ ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្ត និងមិនទាន់អនុវត្តបានពេញលេញក្នុងដំណាក់កាលទី១**

សកម្មភាព ១.១ បញ្ចប់ការរៀបចំអង្គមន្ត្រីរាជការស៊ីវិលក្នុងមុខងារសាធារណៈ

សកម្មភាព ១.២ រៀបចំកែសម្រួល និងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ

សកម្មភាព ១.៣ ត្រួតពិនិត្យឡើងវិញនៃការគ្រប់គ្រងក្នុងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់អង្គភាពផ្តល់សេវាសាធារណៈ

សកម្មភាព ១.៤ បន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈតាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាព័ត៌មានវិទ្យា និងនវានុវត្តន៍

**ចង្កោមសកម្មភាព ២៖ ការដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម**

សកម្មភាព ២.១ លើកកម្ពស់ការផ្តល់សេវាសាធារណៈតាមចង្កោមសេវាសាធារណៈ ថ្មីៗ

សកម្មភាព ២.២ កែសម្រួលនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់មន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

សកម្មភាព ២.៣ ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មចំនួន១០ក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច និងអង្គភាពប្រកចេញចូលតែមួយ ទីភ្នាក់ងារប្រតិបត្តិការពិសេស

**ចង្កោមសកម្មភាព ៣៖ ការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម**

សកម្មភាព ៣.១ រៀបចំនិងដាក់ឱ្យអនុវត្តនូវការផ្តល់ព័ត៌មានត្រឡប់តាមប្រព័ន្ធអេឡិចត្រូនិក

សកម្មភាព ៣.២ ត្រួតពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច

សកម្មភាព ៣.៣ កែលម្អឡើងវិញនូវប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

### ២.៥.៣. ដំណាក់កាលទី៣(២០២៧-២០៣០)៖ គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ

បន្ទាប់ពីការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តសកម្មភាពកែទម្រង់ដំណាក់កាលទី២ សកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដំណាក់កាលទី៣ និងត្រូវអនុវត្តចាប់ពីឆ្នាំ២០២៧ ដល់ឆ្នាំ២០៣០ ដើម្បីលើកកម្ពស់គណនេយ្យភាពសមិទ្ធកម្មសេវាសាធារណៈ។ រដ្ឋបាលសាធារណៈនិងមន្ត្រីរាជការ ត្រូវបានរំពឹងថាមានដំណើរការនិងបំពេញការងារប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជន។

**ចង្កោមសកម្មភាព ១៖ ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្ត និងមិនទាន់អនុវត្តបានពេញលេញក្នុងដំណាក់កាលទី២**

**ចង្កោមសកម្មភាព ២៖ សេវាសាធារណៈប្រកបដោយឧត្តមភាព**

**ចង្កោមសកម្មភាព ៣៖ ការត្រួតពិនិត្យនិងវាយតម្លៃគណនេយ្យភាពសមិទ្ធកម្មចំពោះ សេវាសាធារណៈ**

# ជំពូកទី៣៖ ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

## ៣.១. ដំណាក់កាលនៃការអនុវត្តកម្មវិធីជាតិ

ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ គឺត្រូវអនុវត្តជាដំណាក់កាលៗ ក្នុងនោះការចាប់ផ្ដើមអនុវត្តដំណាក់កាលទី១ គិតចាប់ពីឆ្នាំ២០១៩ដល់ឆ្នាំ២០២៣ ផ្ដោតគោលដៅសំខាន់ទៅលើការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈដំណាក់កាលទី២ពីឆ្នាំ២០២៣ដល់ឆ្នាំ២០២៧ ផ្ដោតគោលដៅសំខាន់ទៅលើការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ និងដំណាក់កាលទី៣ពីឆ្នាំ២០២៧ដល់ឆ្នាំ២០៣០ដោយផ្ដោតគោលដៅសំខាន់ទៅលើគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ។

ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ អាចប្រព្រឹត្តទៅបាន គឺទាមទារឱ្យមានការចូលរួមពីគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនានា និងភាគីពាក់ព័ន្ធនានាសំដៅធានាបាននូវអភិបាលកិច្ចក្នុងការអនុវត្តសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ។

## ៣.២. យន្តការស្ថាប័នសម្រាប់ការអនុវត្តកម្មវិធីជាតិ

តារាងខាងក្រោម នឹងបង្ហាញពីតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនេះគឺជាភាពចាំបាច់ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ។ ហើយការរៀបចំនេះ គឺជាវិធីសាស្ត្រថ្មីមួយក្នុងការអនុវត្តដែលទាមទារឱ្យមានកិច្ចសហការចូលរួមអនុវត្តគ្រប់កម្រិត។

| ក្រសួងស្ថាប័ន និងថ្នាក់ក្រោមជាតិ | តួនាទីភារកិច្ច និងការទទួលខុសត្រូវ |
|---|---|
| ក្រសួងមុខងារសាធារណៈនិងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ | • ដឹកនាំ សម្របសម្រួល ជំរុញ គាំទ្រការអនុវត្ត<br>• តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនូវសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ<br>• លើកកម្ពស់ឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍ និងសាធារណៈជនក្នុងការអនុវត្តសកម្មភាពកំណែទម្រង់រដ្ឋបាលសាធារណៈ និងចែករំលែកព័ត៌មានពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិជូនដល់គ្រប់ភាគីពាក់ព័ន្ធនានា<br>• ពិនិត្យមើល និងដាក់ចេញនូវសំណើក្នុងការផ្តល់សេវាសាធារណៈតាមបច្ចេកវិទ្យាឌីជីថលនិងនវានុវត្តន៍ |
| លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាល | • ជួយគាំទ្រដល់ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការសម្របសម្រួល គាំទ្រការអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តនូវសកម្មភាពការងារកែទម្រង់ |

| | |
|---|---|
| សាធារណៈ | រដ្ឋបាល សាធារណៈ ព្រមទាំងផ្សព្វផ្សាយសកម្មភាពពាក់ព័ន្ធនានា<br>• ផ្សព្វផ្សាយនូវលទ្ធផលនៃការអនុវត្តនិងការវិវត្តន៍នៃរដ្ឋបាលសាធារណៈ ជូនដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍនានា គ្រឹះស្ថានសាធារណៈ សហគ្រាស សាធារណៈ សាកលវិទ្យាល័យ អង្គការសង្គមស៊ីវិល និងសាធារណៈជនអំពីការកែទម្រង់រដ្ឋបាលសាធារណៈ<br>• សម្របសម្រួល សហការ គាំទ្រ និងផ្តល់ ជំនួយបច្ចេកទេសដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈ |
| **ក្រសួងស្ថាប័ន និងរាជធានីខេត្ត** | • ត្រូវរៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបន្សុំទៅនឹងផែនការសកម្មភាពដែលបានកំណត់ក្នុងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈនិងផ្សារភ្ជាប់ជាមួយនឹងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរាជធានីខេត្ត<br>• ត្រូវផ្តល់កិច្ចសហការជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងមុខងារសាធារណៈ ក្នុងការអនុវត្ត ការស្វែងរកនិងប្រមូលព័ត៌មាន ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ព្រមទាំងការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ<br>• ត្រូវមានភាពជាអ្នកដឹកនាំក្នុងការអនុវត្តគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី គោលនយោបាយ យុទ្ធសាស្ត្រ និង សកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ជាពិសេសត្រូវបង្កើតឱ្យមានយន្តការឬយុទ្ធសាស្ត្រក្នុងការអនុវត្តការផ្លាស់ប្តូរប្រកបដោយប្រសិទ្ធភាព ព្រមជាមួយនឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ<br>• ត្រូវយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ តាមរយៈការលើកកម្ពស់ឱ្យមានការប្រឡងប្រណាំងអង្គភាពគំរូក្នុងការផ្តល់សេវាសាធារណៈ និងបង្កើតគណៈកម្មាការសម្រាប់តាមដានត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាសាធារណៈដើម្បីធានាបាននូវសុក្រឹត្យភាពនៃការប្រឡងប្រណាំងអង្គភាពគំរូ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន<br>• ត្រូវរៀបចំចង្រ្កងសេវារួមតែមួយ និងកំណត់ពីចំនួននិងសេវាអាទិភាពដែលត្រូវកែលម្អនិងលើកកម្ពស់គុណភាពដោយត្រូវធ្វើទំនើបកម្មតាមរយៈប្រព័ន្ធឌីជីថល |

កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ស្ថិតនៅក្នុងបរិបទនៃកំណែទម្រង់របស់រាជរដ្ឋាភិបាល ក្នុងគោលបំណងធ្វើទំនើបកម្មមុខងារសាធារណៈ និងលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ។ ការអនុវត្តកែទម្រង់រដ្ឋបាលសាធារណៈ គឺមិនអាចអនុវត្តតែម្នាក់ឯងបានទេដែលទាមទារឱ្យមានចូលរួម និងកិច្ចសហការពីលេខាធិការដ្ឋានកែទម្រង់ផ្សេងទៀតដែលជាផ្នែកមួយនៃដំណើរការនៃគ្រប់គ្រងការផ្លាស់ប្តូរ។ នៅក្នុងបរិយាកាសដ៏ស្មុគស្មាញនៃការផ្លាស់ប្តូរនេះ នឹងតម្រូវឱ្យមានយន្តការអន្តរស្ថាប័នប្រកបដោយប្រសិទ្ធភាព ដើម្បីធានាដល់ដំណើរនៃកិច្ចសហការ វឌ្ឍនភាពការងារត្រូវបានវាស់វែង យុទ្ធសាស្ត្រនានាត្រូវបានបង្កើតដើម្បីដោះស្រាយបញ្ហា និង/ឬឧបសគ្គ ដែលកើតមានឡើង។ ចំណុចនេះនឹងតម្រូវឱ្យមានការពិគ្រោះយោបល់ សម្របសម្រួល និងកិច្ចសហការជាទៀងទាត់ក្នុងចំណោមលេខាធិការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល និងកម្មវិធីកែទម្រង់តាមវិស័យផ្សេងៗទៀត ជាពិសេសត្រូវធ្វើការប្រាស្រ័យទាក់ទងគ្នាឱ្យមានភាពសកម្មខ្លាំងឡើង។

## ជំពូកទី៤៖ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ

ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានលេខាធិការដ្ឋានជាសេនាធិការ ត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈផ្អែកលើសូចនាករសមិទ្ធកម្មច្បាស់លាស់ដើម្បីធ្វើការតាមដានត្រួតពិនិត្យនិងវាយតម្លៃជាប្រចាំត្រីមាស ឆមាស ឆ្នាំ និងពាក់កណ្តាលអាណត្តិ(២ឆ្នាំម្តង)។

លទ្ធផលនៃការតាមដានត្រួតពិនិត្យ និងវាយតម្លៃនេះ នឹងត្រូវរំលេចឡើងនូវវឌ្ឍនភាពការងារ បញ្ហាប្រឈម និងវិធានការអនុវត្តបន្ត ដើម្បីដាក់ជូនគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពិនិត្យ និងសម្រេចមុនពេលផ្សព្វផ្សាយដល់ក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ ព្រមទាំងដៃគូអភិវឌ្ឍពាក់ព័ន្ធនានា។

### ៤.១. សូចនាករគោលនៃសមិទ្ធកម្មរបស់កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ




ដើម្បីតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ សូចនាករគោលនៃសមិទ្ធកម្ម ត្រូវបានកំណត់ដូចខាងក្រោម៖

១. ការគ្រប់គ្រងទំហំមន្ត្រីសាធារណៈឱ្យស្ថិតនៅក្នុងស្ថានភាពដដែល ឬមានកំណើនប្រមាណ៣%

២. ចំនួន១/៣ នៃក្រសួង ស្ថាប័ននិងថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម

៣. ចំនួនសេវាសាធារណៈ ៣០% ត្រូវបានកាត់បន្ថយនីតិវិធីនិងរយៈពេលនៃការផ្តល់សេវាក្នុងចំនួន ៧៥០សេវានៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៤. យ៉ាងតិច១២០សេវាដែលបច្ចុប្បន្នមិនមែនជាទម្រង់សេវាឌីជីថល ត្រូវបានផ្តល់ក្នុងទម្រង់ជាឌីជីថល

ការសម្រេចបាននូវសូចនាករទាំង៤ខាងលើ គឺឆ្លុះបញ្ចាំងអំពីការសម្រេចបានគោលបំណងដែលបានកំណត់ខាងលើ។ សូចនាករនេះ អាចមានការប្រែប្រួល ឬកែប្រែតាមដំណាក់កាលនៃការអនុវត្តក្នុងរយៈពេលមធ្យមនិងរយៈពេលវែង។

វិធីសាស្ត្រក្នុងការវាស់វែងសូចនាករគោលខាងលើ ត្រូវផ្តោតទៅលើធាតុចេញ(Output) លទ្ធផល(Outcome) និងផលប៉ះពាល់(Impact) នៃការអនុវត្តកម្មវិធីជាតិ។ ទន្ទឹមនេះ ការវាស់វែងសូចនាករនេះ គឺត្រូវរៀបចំឱ្យមានក្របខណ្ឌលទ្ធផលមួយជាក់លាក់ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាល។

## ៤.២. ប្រព័ន្ធរបាយការណ៍

ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានលេខាធិការដ្ឋានជាសេនាធិការ ត្រូវទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជាប្រចាំ ឆមាស និងឆ្នាំ ក្នុងនោះត្រូវបង្ហាញពីលទ្ធផល និង/ឬវឌ្ឍនភាពការងារ បញ្ហាប្រឈម សំណូមពរ និងវិធានការអនុវត្តនានា ព្រមជាមួយនឹងការលើកទិសដៅសកម្មភាពបន្តជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យនិងអនុម័តមុននឹងធ្វើការផ្សព្វផ្សាយជាសាធារណៈ។ ជាមួយគ្នានេះ លេខាធិការដ្ឋាន គ.ក.រ ត្រូវរៀបចំឱ្យមានឯកសារគំរូស្តង់ដារបាយការណ៍អំពីលទ្ធផលនៃការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ ដោយមានបញ្ជាក់ពីវិហ្សរទិន្នន័យ ឧបករណ៍ប្រមូលទិន្នន័យ ការរក្សាទុកទិន្នន័យ និងការវិភាគទិន្នន័យ ព្រមជាមួយនឹងតួនាទីរបស់អ្នកពាក់ព័ន្ធ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ត្រូវផ្តល់របាយការណ៍ជាទៀងទាត់ប្រចាំឆមាស និងឆ្នាំ ប្រកបដោយស្មារតីភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់មកលេខាធិការដ្ឋាន គ.ក.រ នៃក្រសួងមុខងារសាធារណៈ ដើម្បីបូកសរុបលទ្ធផលនៃការ អនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងរាយការណ៍ជូនរាជរដ្ឋាភិបាល។

របាយការណ៍លទ្ធផលនៃការអនុវត្តកម្មវិធីជាតិ ដែលក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត ត្រូវផ្តល់មកឱ្យលេខាធិការដ្ឋាន គ.ក.រ នៃក្រសួងមុខងារសាធារណៈ ត្រូវផ្អែកតាមឯកសារគំរូស្តង់ដារបាយការណ៍ ដែលរៀបចំឡើងដោយគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។

## ៤.៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដែលមានលេខាធិការដ្ឋាន គ.ក.រ ជាសេនាធិការ ត្រូវរៀបចំឱ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យលើការអនុវត្តកម្មវិធីជាតិ

កំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីប្រើប្រាស់សម្រាប់ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចនានា ពាក់ព័ន្ធនឹងការកែទម្រង់រដ្ឋបាលសាធារណៈ។

ប្រព័ន្ធតាមដានត្រួតពិនិត្យនៃការអនុវត្តកម្មវិធីជាតិនេះ ត្រូវកំណត់អំពីយន្តការអនុវត្តឱ្យបានជាក់ច្បាស់ រួមមាន ការកំណត់នូវសូចនាករ មធ្យោបាយផ្ទៀងផ្ទាត់ ប្រភេទទិន្នន័យ និងអង្គភាព ឬស្ថាប័នទទួលខុសត្រូវ ដើម្បីជាមូលដ្ឋានក្នុងការប្រមូល វិភាគ និងសំអាតទិន្នន័យសម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងវិភាគលើដំណើរការនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្អែកលើសូចនាករគន្លឹះដែលបានបង្ហាញក្នុងចំណុច៤.១ និងនៅក្នុងតារាងផែនការសកម្មភាព។

លេខាធិការដ្ឋាន គ.ក.រ ត្រូវចុះតាមដានត្រួតពិនិត្យជាប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ លើការអនុវត្តសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ និងរៀបចំដាក់ចេញជារបាយការណ៍បច្ចេកទេសដែលបង្ហាញពីស្ថានភាពជាក់ស្តែងនៃការអនុវត្ត និងលើកជាមតិយោបល់ និង/ឬ ផ្តល់ជាអនុសាសន៍សម្រាប់វិធានការណ៍អនុវត្តបន្តជូនដល់គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពិនិត្យនិងសម្រេច។

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈតាមក្រសួងស្ថាប័ន និងរាជធានី ខេត្ត ត្រូវចូលរួម និងសហការជាមួយលេខាធិការដ្ឋាន គ.ក.រ ក្នុងការចុះតាមដានត្រួតពិនិត្យលើការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ថាតើការអនុវត្តទទួលបានលទ្ធផលកម្រិតណា ជួបប្រទះបញ្ហាប្រឈមអ្វីខ្លះ ហើយអ្វីដែលជាតម្រូវការចាំបាច់និងវិធានការណ៍សម្រាប់ការដោះស្រាយបន្ទាប់។

លទ្ធផលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើការអនុវត្តកម្មជាតិកំណែទម្រង់រដ្ឋបាលសាធារណៈត្រូវដាក់ឆ្លងកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីពិនិត្យ និងអនុម័ត។

## ជំពូកទី៥៖ ប្រភពធនធាននិងគោលការណ៍លើកទឹកចិត្តដែលគាំទ្រដល់ការរៀបចំនិងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ប្រភពធនធានដែលគាំទ្រដល់ការរៀបចំនិងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ អាចទទួលបានពីប្រភពថវិកាជាតិ ព្រមទាំងហិរញ្ញប្បទាននិងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍនានា។

ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ រាជរដ្ឋាភិបាល នឹងផ្តល់ការលើកទឹកចិត្តទាំងផ្នែកហិរញ្ញវត្ថុ និង/ឬ មិនមែនហិរញ្ញវត្ថុដល់មន្ត្រី ក្រុមការងារ អង្គភាព ក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបំពេញការងារក្នុងក្របខណ្ឌនៃការផ្តួចផ្តើម ដឹកនាំ គ្រប់គ្រង សម្របសម្រួល គាំទ្រ និងជំរុញការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

ថវិកាសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ គឺមានប្រភពមកពីថវិកាជាតិ ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ និងប្រភពថវិកាស្របច្បាប់ផ្សេងទៀត។ ថវិកាសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ២០១៩-២០៣០ ត្រូវអនុវត្តទៅតាមថវិកាកម្មវិធីនិងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ជំពូកទី៦៖ សេចក្តីសន្និដ្ឋាន

ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈកន្លងមក រាជរដ្ឋាភិបាលកម្ពុជា សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនមានដូចជា៖

- ការកសាងនូវមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ធ្វើវិចារណកម្ម រចនាសម្ព័ន្ធ មន្ត្រីរាជការនៅតាមក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- លើកកម្ពស់អភិបាលកិច្ចល្អ និងនីតិរដ្ឋក្នុងរដ្ឋបាលសាធារណៈ
- កែលម្អគោលនយោបាយបៀវត្សប្រាក់បៀវត្សជូនមន្ត្រីរាជការ
- រៀបចំគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ គោលនយោបាយស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្ស និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

ទោះបីជាយ៉ាងនេះក៏ដោយ សមិទ្ធផលទាំងនេះ នៅមិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលនៅឡើយដែលចាំបាច់ត្រូវបន្តធ្វើការកែទម្រង់បន្តទៅទៀត តាមរយៈការធ្វើទំនើបកម្មរដ្ឋបាលសាធារណៈ ដោយជំរុញឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការផ្តល់សេវាស្របតាមស្តង់ដាសេវាសាធារណៈក្នុងការអភិវឌ្ឍ និងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលនិងក្នុងការបន្តកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ទាប់បន្សំផ្សេងៗរបស់មន្ត្រីរាជការ ដើម្បីគាំទ្រដល់ប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានមនុស្ស និងលើកកម្ពស់គុណភាពសេវាសាធារណៈ។

នៅក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានចង្អុលបង្ហាញពីគោលដៅជាយុទ្ធសាស្ត្រនៃកំណែទម្រង់អភិបាលកិច្ចក្នុងការធ្វើទំនើបកម្មស្ថាប័នរដ្ឋ និងការធានានិរន្តរភាពនៃតួនាទីនិងដំណើរការរដ្ឋបាលសាធារណៈ។ ក្រសួងមុខងារសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ បានរៀបចំកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៩-២០៣០ មានចក្ខុវិស័យដើម្បីធានាឱ្យបាននូវ **រដ្ឋបាលសាធារណៈ ស្អាតស្អំ ឆ្លាតវៃ ខ្លាំង និងផ្តោតលើប្រជាជនជាស្នូល** សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គមប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌។

ការអនុវត្តកម្មវិធីជាតិនេះ គឺត្រូវអនុវត្តជា៣ដំណាក់កាល ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងដៃគូអភិវឌ្ឍនានា ដោយបញ្ចូលផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈទៅនឹងផែនការ យុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទន្ទឹមនេះ ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈដែលផ្តោតទៅលើការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ការពង្រឹងប្រសិទ្ធភាពការងារនៃការអនុវត្តការងារ និងការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម គឺជាកត្តាគន្លឹះដើម្បី

**ឧបសម្ព័ន្ធ ១៖ សាវតានិងសមិទ្ធផលសង្ខេបនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ**

ក្រោយការបោះឆ្នោតជាសកលឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវកម្មវិធីនយោបាយឯកសារយុទ្ធសាស្ត្ររបស់ខ្លួន ដោយបានចាត់ទុកកំណែទម្រង់គ្រប់វិស័យ និងការរក្សាឱ្យបានសន្តិភាពស្ថិរភាពនយោបាយ ជាពិសេសការងារកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលជាការងារបន្ទាន់ និងអាទិភាពបំផុតចំពោះមុខ។ តាមរយៈការអនុវត្តនយោបាយ "**ឈ្នះ-ឈ្នះ**" ដែលឈរលើមូលដ្ឋាននៃស្មារតីមហាសាមគ្គីជាតិនិងឯកភាពជាតិ រាជរដ្ឋាភិបាលសម្រេចបាននូវការកសាងមូលដ្ឋានគ្រឹះនៃសន្តិភាពស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលជាបុរេលក្ខខណ្ឌដ៏ចាំបាច់បំផុតសម្រាប់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។

ឈរលើមូលដ្ឋានគ្រឹះនៃសុខសន្តិភាពនិងស្ថិរភាពនយោបាយនេះ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ក្នុងការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈចាប់តាំងពីឆ្នាំ១៩៩៣ រហូតមកដល់បច្ចុប្បន្ន ទៅតាមអាណត្តិរបស់រាជរដ្ឋាភិបាល ដោយសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

**ឆ្នាំ១៩៩៣-១៩៩៨**: រាជរដ្ឋាភិបាល បានធ្វើសមាហរណកម្មភាគីនយោបាយទាំងអស់ ដែលជាហត្ថលេខីនៃកិច្ចព្រមព្រៀងក្រុងប៉ារីស រួមទាំងនិស្សិតសរុបចំនួនប្រហែល ២៥ ០០០នាក់ ទៅក្នុងប្រព័ន្ធរដ្ឋបាលឯកភាពជាតិតែមួយក្នុងគោលដៅបញ្ចប់ទាំងស្រុងនូវសង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុង និងផ្តល់ការងារដល់និស្សិតដែលបានបញ្ចប់ការសិក្សាមកពីបរទេសដើម្បីរួមគ្នាស្តារនិងកសាងប្រទេសជាតិឡើងវិញ និងបានរៀបចំដាក់ឱ្យអនុវត្តច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន អនុក្រឹត្យស្តីពីការដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សអនុក្រឹត្យស្តីពីគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ព្រមទាំងបានរៀបចំបទដ្ឋានគតិយុត្តជាច្រើនទៀតពាក់ព័ន្ធនឹងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល។

**ឆ្នាំ១៩៩៩-២០០៣** : ការកែទម្រង់រដ្ឋបាលសាធារណៈ បានប្រព្រឹត្តទៅជា ៣ ដំណាក់កាល៖ **(១) ការ**ពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ **(២)**ការរៀបចំសម្រួលរចនាសម្ព័ន្ធ និងការពង្រាយមន្ត្រីរាជការ **(៣)**ការធ្វើសនិទានកម្មមុខងារសាធារណៈ និងការអភិវឌ្ឍធនធានមនុស្ស។ ដំណាក់កាលនីមួយៗត្រូវបានអនុវត្តដោយផ្អែកលើអ័ក្ស៤គឺ៖ **(១)**ពង្រឹងស្ថាប័នរដ្ឋដោយពង្រឹងនីតិរដ្ឋក្នុង រដ្ឋបាល **(២)** កែលម្អប្រព័ន្ធរដ្ឋបាលនិងអន្តរសកម្មរវាងស្ថាប័នតាមរយៈការពង្រឹងការងារអភិបាលកិច្ចល្អ **(៣)**អភិវឌ្ឍន៍ធនធានមនុស្ស ដើម្បីពង្រឹងប្រសិទ្ធភាពរដ្ឋបាលសាធារណៈ និង**(៤)**គ្រប់គ្រងការផ្លាស់ប្តូរ។

សមិទ្ធផលដែលសម្រេចបានរួមមាន៖ បានធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ដោយបានរកឃើញ និងលុបចេញពីក្របខណ្ឌនូវមន្ត្រីដែលមានតែឈ្មោះក្នុងបញ្ជី(មន្ត្រីខ្មោច) និងមន្ត្រីមិនប្រក្រតីផ្សេងៗទៀតចំនួនជាង១ម៉ឺននាក់ បានកសាងមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិល បានបង្កើតលក្ខន្តិកៈដោយឡែកតាមប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិលចំនួន២១ប្រភេទក្របខណ្ឌ បានបង្កើតនិងដាក់ឱ្យអនុវត្តប្រព័ន្ធលាភការថ្មី បានធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធលាភការថ្មី

បានបង្កើតនិងដាក់ឱ្យដំណើរការប្រព័ន្ធចំណាត់ថ្នាក់ថ្មីដែលមាន ៤ ប្រភេទក្របខណ្ឌ ដោយក្របខណ្ឌនីមួយៗមាន ៣ ឋានន្តរស័ក្តិ និងចែកចេញជាថ្នាក់ បានបង្កើតនិងដាក់ឱ្យដំណើរការតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា បានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រសនិទានកម្មមុខងារសាធារណៈ បានរៀបចំឲ្យមានប្រាក់បំណាច់មុខងារតាមវិស័យជូនមន្ត្រីរាជការស៊ីវិល និងបានដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលជាបន្តបន្ទាប់ ។

**ឆ្នាំ២០០៤-២០០៨** : ការកែទម្រង់រដ្ឋបាលសាធារណៈ ផ្តោតលើគោលដៅ៖(១)ការកែលម្អសេវាសាធារណៈ (២)ការបង្កើនបៀវត្សនិងពង្រឹងការគ្រប់គ្រងនិយោជន៍ (៣)ការអភិវឌ្ឍសមត្ថភាព និង (៤)ការជំរុញប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ សមិទ្ធផលដែលសម្រេចបាន រួមមាន៖ បានកសាងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ បានចងក្រងកម្រងព័ត៌មានសេវាសាធារណៈ បានកំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែកនៃប្រភេទ ក្របខណ្ឌនីមួយៗ បានដាក់ឱ្យអនុវត្តកម្មវិធីកន្សោមអាទិភាព ប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ទីភ្នាក់ងារប្រតិបត្តិការពិសេស បានដំឡើងប្រាក់បៀវត្សប្រចាំឆ្នាំជូនមន្ត្រីរាជការស៊ីវិលតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល បានកែសម្រួលគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានចូលរួមបង្កើតឱ្យមានបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បានពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យក្របខណ្ឌមន្ត្រីរាជការ ។

**ឆ្នាំ២០០៨-២០១២** : រាជរដ្ឋាភិបាល បានបន្តអនុវត្តកំណែទម្រង់កាន់តែស៊ីជម្រៅនិងទូលំទូលាយថែមទៀត ដោយផ្តោតគោលដៅ៖ **(១)**ប្រែក្លាយ "រដ្ឋបាលសាធារណៈពីអ្នកគ្រប់គ្រងឱ្យទៅជាអ្នកផ្តល់សេវាសាធាណៈជូនប្រជាពលរដ្ឋ" **(២)**ធ្វើឱ្យរដ្ឋបាលសាធារណៈកាន់តែមានតម្លាភាព ភាពឆ្លើយតប ប្រសិទ្ធភាពនិងប្រសិទ្ធផល និង**(៣)**លើកកម្ពស់គុណសម្បត្តិនៃវប្បធម៌សេវាសាធារណៈ ភក្តីភាព ឆន្ទៈម្ចាស់ការ និងមនសិការវិជ្ជាជីវៈ។ ដើម្បីសម្រេចគោលដៅខាងលើ ការកែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុវត្តតាមយុទ្ធសាស្ត្រ៖ **(១)**ពង្រឹងតម្លាភាពក្នុងដំណើរការនៃការបង្កើនគុណភាពសេវាសាធារណៈ **(២)**ពង្រឹងគណនេយ្យភាពក្នុងការបង្កើនប្រសិទ្ធភាពសេវាសាធារណៈ **(៣)**អភិវឌ្ឍធនធានមនុស្សនិងស្ថាប័ន **(៤)**ពង្រឹងការគ្រប់គ្រងធនធានមនុស្សនិងបៀវត្ស និង**(៥)**ពង្រឹងការគ្រប់គ្រងក្របខណ្ឌនិងការពង្រាយមន្ត្រីរាជការ។

លទ្ធផលដែលសម្រេចបានរួមមាន ៖ បានបញ្ចប់ការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចទី២ បានចងក្រងបោះពុម្ពនិងផ្សព្វផ្សាយកម្រងព័ត៌មានសេវាសាធារណៈចំនួន ៦ ចង្កោម បានរៀបចំអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ បានបង្កើតគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ បានបង្កើតឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ បានដាក់ឱ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាព និងបានលើកកម្ពស់សមត្ថភាពមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលទាំងក្នុងនិងក្រៅប្រទេស។

**ឆ្នាំ២០១៣-២០១៨** : រាជរដ្ឋាភិបាលកម្ពុជា បានអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ ដោយផ្តោតលើគោលដៅ៖ **(ទី១)**សេវាសាធារណៈប្រកបដោយគុណភាព មានភាពសាមញ្ញ ប្រសិទ្ធភាព ភាពអាចជឿទុកចិត្តបាន ភាពឆាប់រហ័ស ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការ មានភាពងាយស្រួល

និងមានការចូលរួមពីអ្នកប្រើប្រាស់សេវា (**ទី២**)ការគ្រប់គ្រង និងការអភិវឌ្ឍមន្ត្រីរាជការស៊ីវិលឱ្យកាន់តែមានសមត្ថភាព ភាពស្វាហាប់ ប្រសិទ្ធភាព និងភាពជឿទុកចិត្តក្នុងការផ្តល់សេវាសាធារណៈ ដោយប្រកាន់ភ្ជាប់នូវវប្បធម៌សេវាសាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ និង(**ទី៣**)ប្រព័ន្ធបៀវត្សដែលធានាបាននូវសមធម៌ បង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ព្រមទាំងធានាបាននូវសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខណ្ឌកងកម្លាំងប្រដាប់អាវុធ។

សមិទ្ធផលសំខាន់ៗ ដែលសម្រេចបាន រួមមានៈ បានដាក់ឱ្យអនុវត្តកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមរយៈទូរស័ព្ទស្មាតហ្វូន ប្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ បានពង្រីកការអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស និងដាក់ឱ្យអនុវត្តការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងសុខាភិបាល។

ទន្ទឹមនេះ រាជរដ្ឋាភិបាល បានកែសម្រួលគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ និងការពន្លឿននីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ បានដាក់ឱ្យអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទដ្ឋានគតិយុត្តនានានិងឯកសារណែនាំមួយចំនួនទៀតដើម្បីពង្រឹងការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិល មន្ត្រីកិច្ចសន្យា ការគ្រប់គ្រងរចនាសម្ព័ន្ធនិងចំនួនមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ព្រមជាមួយនឹងការធ្វើប្រតិភូកម្មអំណាចក្នុងការតែងតាំងផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានដាក់ចេញនូវការណែនាំនិងគំរូនៃការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មុខតំណែងគ្រប់គ្រងដល់គ្រប់ក្រសួង ស្ថាប័ន ដែលក្នុងនោះក្រសួងស្ថាប័នចំនួន០៩ បានរៀបចំនិងបញ្ចប់សព្វគ្រប់លើការរៀបចំការពិពណ៌នាមុខតំណែង។ រាជរដ្ឋាភិបាលបានរៀបចំវគ្គបណ្តុះបណ្តាលជាប្រព័ន្ធនិងជាកាតព្វកិច្ចដល់មន្ត្រីរាជការ តាមរយៈសាលាភូមិន្ទរដ្ឋបាលដោយផ្តោតទៅលើការបណ្តុះបណ្តាលសម្រាប់កម្រិតថ្នាក់ដឹកនាំ កម្រិតគ្រប់គ្រង និងមន្ត្រីក្របខណ្ឌថ្មីព្រមទាំងកម្រិតថ្នាក់ដឹកនាំជាស្ត្រី។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាល រៀបចំប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យមានសង្គតិភាពនឹងគ្នា ក្នុងនោះ បានដំឡើងប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ ផ្សេងៗជូនដល់មន្ត្រីរាជការកម្រិតអប្បបរមាទទួលបានចំនួនច្រើនជាងមួយលានរៀល និងបើកផ្តល់បានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗតាមប្រព័ន្ធធនាគារ និងបានដាក់ឱ្យអនុវត្តការកាត់ពន្ធបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលតាមតារាងទូទាត់បៀវត្សដោយស្វ័យប្រវត្តិ ព្រមទាំងបានដាក់ឱ្យអនុវត្តការផ្តល់ប្រាក់វិភាជន៍គ្រួសារសម្រាប់កូនមន្ត្រីរាជការរហូតដល់អាយុ២១ឆ្នាំដោយស្វ័យប្រវត្តិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល បានដំឡើងប្រាក់សោធននិវត្តន៍ប្រចាំខែជូននិវត្តន៍ជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល ព្រមទាំងបានដំឡើងប្រាក់ឧបត្ថម្ភ មាតុភាពជូនមន្ត្រីរាជការ មន្ត្រីកម្មសិក្សានិងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសព។

ក្រៅពីនេះ រាជរដ្ឋាភិបាល បានដំឡើងប្រាក់បំណាច់មុខងារ ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភ ប្រាក់បំណាច់ និងបច្ច័យនិច្ចកត្តជូនដល់ មន្ត្រីរាជការ មន្ត្រីកិច្ចសន្យា កងកម្លាំងប្រដាប់អាវុធ សមាជិករាជរដ្ឋាភិបាល ទីប្រឹក្សា ជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ មន្ត្រីឧទ្ទកាល័យ គ្រូពុទ្ធិកសិក្សា

ចៅក្រមនិងព្រះរាជអាជ្ញា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិ ព្រមទាំងផ្តល់ជូននូវប្រាក់ឧបត្ថម្ភសម្រាប់សហព័ទ្ធនិងកូនរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការនិងបុគ្គលិកបំពេញការកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស និងប្រាក់តំបន់សម្រាប់វិស័យអប់រំ និងវិស័យសុខាភិបាល។

# ឧបសម្ព័ន្ធ២៖ តារាងផែនការសកម្មភាព-កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល២០១៩-២០៣០

| ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំអនុវត្ត | | | | | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|---|
| | | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ | |
| **គោលដៅ (ដំណាក់កាលទី១ ២០១៩-២០២៣) : ការពង្រឹងសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ** | | | | | | | |
| **១.ការកែទម្រង់និងលើកកម្ពស់សមត្ថភាពស្ថាប័នសាធារណៈ** | | | | | | | |
| **១.១** ធ្វើវិចារណកម្មមុខងារ ភារកិច្ច រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ននិងការសម្របសម្រួលអន្តរស្ថាប័ន ដោយផ្តោតជាសំខាន់លើការពង្រឹងភាពជាម្ចាស់ ការទទួលខុសត្រូវ និងបន្ទាត់គណនេយ្យភាពច្បាស់លាស់របស់ក្រសួង ស្ថាប័ននីមួយៗ | រចនាសម្ព័ន្ធគ្រប់គ្រង មុខងារ ទំហំបុគ្គលិក ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ជាក់លាក់ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន |
| ១.១.១. សិក្សា និងវិភាគអំពីរចនាសម្ព័ន្ធ និងទំហំបុគ្គលិករបស់ក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងដាក់ចេញជាជំរើសសម្រាប់អនុវត្ត | លទ្ធផលនៃការសិក្សាត្រូវបានពិនិត្យនិងរៀបចំបទដ្ឋានគតិយុត្តសម្រាប់អនុវត្ត( សំដៅលើអនុក្រឹត្យលេខ២០ ) | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន |
| ១.១.២. ដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តស្តីពីការធ្វើវិចារណកម្ម រចនាសម្ព័ន្ធ មុខងារ ក្នុងចំណោម ក្រសួងស្ថាប័នថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការជួយគាំទ្រពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈ | ក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តលិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញ | | √ | √ | | | - ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **១.២ ពង្រឹងភាពជាអ្នកដឹកនាំ ស្មារតីម្ចាស់ការប្រកបដោយការទទួលខុសត្រូវខ្ពស់និងសាមគ្គីភាពផ្ទៃក្នុងស្ថាប័ន ការរៀបចំនិងអនុវត្តឲ្យហ្មត់ចត់នូវ ក្របខណ្ឌប្រតិបត្តិសម្រាប់បំពេញ ការងារ និងការសម្រិតសម្រាំងកេមន្ត្រី មានសមត្ថភាពខ្ពស់និងគុណវុឌ្ឍល្អប្រសើរសម្រាប់ការតែងតាំង មុខតំណែងដឹកនាំនៅក្នុងមុខងារសាធារណៈ ព្រមទាំងការលើកកម្ពស់សមត្ថភាព និងតួនាទីរបស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ** | កម្មវិធីនៃការកសាងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីរាជការ និង តួនាទីស្ត្រីក្នុងកម្រិតគ្រប់គ្រងក្នុងវិស័យមុខងារសាធារណៈត្រូវបានលើកកម្ពស់ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន |
| ១.២.១. សិក្សាអំពីតម្រូវការនៃការបណ្តុះបណ្តាល និងកសាងសមត្ថភាពភាពជាអ្នកដឹកនាំសម្រាប់មន្ត្រីសាធារណៈ | - របាយការណ៍លទ្ធផលនៃការសិក្សា<br>- ឯកសារណែនាំស្តីពីការបណ្តុះបណ្តាល<br>- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | | √ | | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន |
| ១.២.២. រៀបចំបង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យជំនាញ និងគុណវុឌ្ឍិមន្ត្រីរាជការ | - ស្តង់ដារគុណវុឌ្ឍិត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | | √ | | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន |
| ១.២.៣. រៀបចំបង្កើតឯកសារយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈ | - ឯកសារយុទ្ធសាស្ត្រស្តីពីការលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យមុខងារសាធារណៈត្រូវរៀបចំឡើងនិងដាក់ឱ្យអនុវត្ត<br>- ចំនួនស្ត្រីនៅក្នុងកម្រិតគ្រប់គ្រងត្រូវបានបង្កើន<br>- ចំនួនស្ត្រីនៅក្នុងវិស័យសាធារណៈត្រូវបានបង្កើន | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួងកិច្ចការនារី<br>- ក្រសួង ស្ថាប័ន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **១.៣ លើកកម្ពស់គុណាធិបតេយ្យក្នុងការជ្រើសរើស ការតែងតាំង ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ ព្រមទាំងការលើកទឹកចិត្ត និងការផ្តល់អត្ថប្រយោជន៍ផ្សេងទៀតដល់មន្ត្រីសាធារណៈនិងអង្គភាពសាធារណៈជាពិសេសការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្មក្នុងវិស័យសាធារណៈ** | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធទៅនឹងការលើកកម្ពស់គុណាធិបតេយ្យ និង ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ<br>- ក្រសួង ស្ថាប័ន |
| ១.៣.១. សិក្សានិងរៀបចំបទដ្ឋានគតិយុត្ត ដើម្បីកែលម្អនីតិវិធី និងយន្តការ នៃការជ្រើសរើស ការតែងតាំងនិងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល | លិខិតបទដ្ឋានគតិយុត្ត ស្តីពីនីតិវិធី និងយន្តការនៃការជ្រើសរើស ការតែងតាំង និងការគ្រប់គ្រងមន្ត្រីរាជការ ត្រូវបានដាក់ឱ្យអនុវត្ត | √ | √ | | | | - ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ |
| ១.៣.២.រៀបចំការពិពណ៌នាមុខតំណែងក្នុងមុខងារសាធារណៈ | ការពិពណ៌នាមុខតំណែងគ្រប់គ្រងនិងមុខតំណែងវិជ្ជាជីវៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តតាមក្រសួង ស្ថាប័ន ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | √ | √ | √ | | | - គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ<br>- ក្រសួង ស្ថាប័ន |
| **១.៤ ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យសាធារណៈ តាមរយៈ ការរៀបចំក្របខណ្ឌច្បាប់និងលិខិតបទដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធការងារ ក្របខណ្ឌ អភិវឌ្ឍន៍មូលធនមនុស្សដែលទាក់ទាញសមត្ថភាពជំនាញនិងទេពកោសល្យ និងការជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដើម្បីលើកកម្ពស់ការគ្រប់គ្រងព័ត៌មាននិងទិន្នន័យមន្ត្រីសាធារណៈ** | - អង្គរដ្ឋបាល និងអង្គវិជ្ជាជីវៈ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត<br>- ការគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យាត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តតាមក្រសួងស្ថាប័ន | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ<br>- ក្រសួង ស្ថាប័ន |
| ១.៤.១.រៀបចំអង្គមន្ត្រីរាជការស៊ីវិលក្នុងរដ្ឋបាលសាធារណៈ | - ព្រះរាជក្រឹត្យ ស្តីពី អង្គរដ្ឋបាល អង្គអប់រំ អង្គសុខាភិបាល និងអង្គវិជ្ជាជីវៈផ្សេងៗទៀត ត្រូវបានដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មការកែទម្រង់រដ្ឋបាលសាធារណៈ<br>- ក្រសួងអប់រំ<br>- ក្រសួងសុខាភិបាល<br>- ក្រសួង ស្ថាប័ន |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១.៤.២.រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា | - ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការត្រូវបានដាក់ឱ្យអនុវត្តតាមក្រសួង ស្ថាប័ន<br>- ប្រព័ន្ធគ្រប់គ្រងទិន្នន័យជំនាញ និង គុណវុឌ្ឍិមន្ត្រីរាជការស៊ីវិលត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត | √ | √ | √ | | | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួង ស្ថាប័ន |
| ១.៤.៣.ផ្តល់សិទ្ធអំណាចដល់អង្គភាពធនធានមនុស្ស និងអភិវឌ្ឍសមត្ថភាពអ្នកជំនាញខាងធនធានមនុស្ស | - សមត្ថភាពរបស់អង្គភាពធនធានមនុស្សត្រូវបានលើកកម្ពស់ក្នុងការចូលរួមគាំទ្រដល់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួង ស្ថាប័ន |
| **២.ពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ** | | | | | | | |
| **២.១ ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីសេវាសាធារណៈ និងពង្រីកការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកប្រើប្រាស់សេវាសាធារណៈ** | ព័ត៌មានស្តីពីសេវាសាធារណៈ របស់គ្រប់ក្រសួង ស្ថាប័នត្រូវបានធ្វើបច្ចុប្បន្នភាព និង ផ្សព្វផ្សាយបានទូលំទូលាយជូនប្រជាពលរដ្ឋ | √ | √ | √ | √ | √ | **- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ**<br>**- ក្រសួង ស្ថាប័ន**<br>**- រដ្ឋបាលថ្នាក់ក្រោមជាតិ** |
| ២.១.១.ធ្វើបច្ចុប្បន្នភាពព័ត៌មានស្តីពីការផ្តល់សេវាសាធារណៈរបស់គ្រប់ក្រសួង ស្ថាប័នជាប្រចាំ | ព័ត៌មានសំខាន់ៗស្តីពីសេវាសាធារណៈ រួមមាន ឈ្មោះសេវា កន្លែងផ្តល់តម្លៃ រយៈពេល ឯកសារតម្រូវ នីតិវិធីនៃការ ផ្តល់សេវា និងលេខទំនាក់ទំនងជាមួយ អង្គភាពផ្តល់សេវា ត្រូវបានធ្វើបច្ចុប្បន្នភាពនិងចងក្រង និងផ្សព្វផ្សាយ | √ | √ | √ | √ | √ | **- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ**<br>**- ក្រសួង ស្ថាប័ន**<br>**- រដ្ឋបាលថ្នាក់ក្រោមជាតិ** |
| ២.១.២.បន្តពង្រីកការផ្សព្វផ្សាយព័ត៌មានស្តីពីសេវាសាធារណៈតាមរយៈ កម្មវិធីទូរស័ព្ទផ្តល់ព័ត៌មានស្តីពីសេវាសាធារណៈ និងគេហទំព័រផ្តល់ព័ត៌មានស្តីពីសេវាសាធារណៈ | កម្មវិធីទូរស័ព្ទផ្តល់ព័ត៌មានស្តីពីសេវា សាធារណៈ និងគេហទំព័រផ្តល់ព័ត៌មាន ស្តីពីសេវាសាធារណៈ ត្រូវបានពង្រីក សមត្ថភាពនិងផ្សព្វផ្សាយកាន់តែទូលំទូលាយអំពីការប្រើប្រាស់ | √ | √ | √ | | | **- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ**<br>**- ក្រសួង ស្ថាប័ន**<br>**- រដ្ឋបាលថ្នាក់ក្រោមជាតិ** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **២.២ កែលម្អនីតិវិធី ឯកសារតម្រូវ និងកាត់បន្ថយរយៈពេលនៃការផ្តល់សេវាសាធារណៈ** | សេវាសាធារណៈរបស់គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោម សរុប ចំនួន៧៥០ សេវា ត្រូវបានកាត់បន្ថយនីតិវិធី ឯកសារតម្រូវនិងរយៈពេលនៃការផ្តល់សេវាយ៉ាងតិច ៣០% ក្នុងរយៈពេល ៥ ឆ្នាំ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២.២.១.សិក្សានិងប្រមូលទិន្នន័យពាក់ព័ន្ធនឹងនីតិវិធី ឯកសារតម្រូវ និងរយៈពេលនៃការផ្តល់សេវារបស់គ្រប់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណត់ជម្រើសសេវាដែលត្រូវកាត់បន្ថយ | ទិន្នន័យស្តីពីនីតិវិធី ឯកសារតម្រូវ និងរយៈពេលនៃការផ្តល់សេវាត្រូវបានប្រមូលចងក្រងសម្រាប់ការវិភាគនិងធ្វើជម្រើសសម្រាប់ការកាត់បន្ថយ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២.២.២.អនុវត្តការកាត់បន្ថយនីតិវិធី ឯកសារតម្រូវនិងរយៈពេលនៃការផ្តល់សេវាសាធារណៈដែលត្រូវបានកំណត់ជាគោលដៅសម្រាប់ការកាត់បន្ថយ | សេវាសាធារណៈរបស់គ្រប់ក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ សរុប ចំនួន៧៥០ សេវា ត្រូវបានកាត់បន្ថយនីតិវិធី ឯកសារតម្រូវនិងរយៈពេលនៃការផ្តល់សេវាយ៉ាងតិច ៣០% ក្នុងរយៈពេល ៥ ឆ្នាំ | √ | √ | √ | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួង ស្ថាប័ន<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ២.២.៣.រៀបចំបង្កើតច្បាប់ស្តីពីសេវាសាធារណៈ និងផ្សព្វផ្សាយឱ្យអនុវត្ត | ច្បាប់ស្តីពីសេវាសាធារណៈត្រូវបានអនុម័ត និងផ្សព្វផ្សាយអនុវត្ត | | √ | √ | √ | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |
| ២.២.៤.លើកកម្ពស់សមត្ថភាពមន្ត្រីផ្តល់សេវាសាធារណៈ ទាំងផ្នែកជួរមុខ និងផ្នែកជួរក្រោយស្តីពីទស្សនាទាននៃការផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈ និងគុណភាព | មន្ត្រីផ្តល់សេវាសាធារណៈទាំងផ្នែកជួរមុខ និងផ្នែកជួរក្រោយរបស់អង្គភាពផ្តល់សេវាសរុបចំនួន ៥០០០ នាក់ បានទទួលការបណ្តុះបណ្តាលស្តីពីទស្សនាទាននៃការផ្តល់សេវាសាធារណៈប្រកបដោយវិជ្ជាជីវៈ និងគុណភាព ត្រឹមឆ្នាំ ២០២៣ | | | | | | - លេខាធិការដ្ឋាន គ.ក.រ<br>- សាលាភូមិន្ទរដ្ឋបាល |
| **២.៣. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយន្តការអធិការកិច្ច និងសវនកម្មផ្ទៃក្នុងវិស័យសាធារណៈ** | យន្តការ និងនីតិវិធីនៃការធ្វើអធិការកិច្ច និងសវនកម្មក្នុងវិស័យសាធារណៈ ត្រូវបានកែសម្រួល និងធ្វើឱ្យមានសុខដុមនីយកម្ម | | √ | √ | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.៣.១. សិក្សា និងត្រួតពិនិត្យឡើងវិញពាក់ព័ន្ធទៅនឹងលិខិតបទដ្ឋានគតិយុត្ត មុខងារ ភារកិច្ចនៃការអនុវត្តរបស់អធិការកិច្ច និងសវនកម្មផ្ទៃក្នុង | របាយការណ៍នៃការសិក្សា ត្រូវបានបញ្ចប់ និងដាក់ចេញជាអនុសាសន៍ និងជម្រើសក្នុងការអនុវត្ត | | √ | √ | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ |
| ២.៣.២.សិក្សានិងដាក់ឱ្យអនុវត្តឯកសារស្តីពីវិធីសាស្ត្រនៃការអនុវត្តយន្តការអធិការកិច្ចនិងសវនកម្មអង្គភាពផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងមានសុខដុមនីយកម្ម | ឯកសារស្តីពីវិធីសាស្ត្រនៃការអនុវត្ត យន្តការអធិការកិច្ចនិងសវនកម្មអង្គភាពផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព និងមានសុខដុមនីយកម្ម ត្រូវបានរៀបចំនិងអនុវត្ត | | √ | √ | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នពាក់ព័ន្ធ |
| **២.៤. ពង្រឹងប្រសិទ្ធភាពរៀបចំនិងអនុវត្តក្រមសីលធម៌ការងារព្រមទាំងគោលការណ៍វិសមតភាពមុខងារនិងទំនាស់ផលប្រយោជន៍នៅក្នុងការបំពេញការងាររបស់មន្ត្រីសាធារណៈ** | ក្រមសីលធម៌មន្ត្រីរាជការ និងយន្តការនៃការដោះស្រាយវិវាទត្រូវបានរៀបចំឡើងនិងដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- អង្គភាពប្រឆាំងអំពើពុករលួយ |
| ២.៤.១. រៀបចំលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការងារគ្រប់គ្រងការពារផលប្រយោជន៍និងដោះស្រាយ វិវាទមុខងារសាធារណៈ | យន្តការនៃការដោះស្រាយវិវាទក្នុងរដ្ឋបាលសាធារណៈត្រូវបានកែលម្អនិងពង្រឹងការអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |
| ២.៤.២. រៀបចំនិងដាក់ឱ្យអនុវត្តនូវក្រមសីលធម៌មន្ត្រីរាជការស៊ីវិល | ក្រមសីលធម៌មន្ត្រីរាជការស៊ីវិលត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |
| ២.៤.៣. អភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈក្នុងការអនុវត្តក្រមសីលធម៌និងពង្រាយធនធានមនុស្សសម្រាប់ការអនុវត្ត | ផែនការអភិវឌ្ឍសមត្ថភាពមន្ត្រីជំនាញនៃក្រសួងមុខងារសាធារណៈត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- អង្គភាពប្រឆាំងអំពើពុករលួយ |
| **២.៥. ជំរុញការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា រួមបញ្ចូលទាំងការពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីគាំទ្រការអនុវត្ត** | យន្តការទទួលនិងដោះស្រាយព័ត៌មានត្រឡប់និងបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅគ្រប់ ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២.៥.១. រៀបចំឯកសារណែនាំស្តីពីការអនុវត្តយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ | គ្រប់អង្គភាពផ្តល់សេវាសាធារណៈនៃក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ អនុវត្តការទទួលព័ត៌មានត្រឡប់ និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈដោយផ្អែកលើឯកសារណែនាំដែលបានរៀបចំនិងផ្សព្វផ្សាយអនុវត្ត | | √ | √ | | | - **ក្រសួងមុខងារសាធារណៈ និង លេខាធិការដ្ឋាន គ.ក.រ** |
| ២.៥.២. ជំរុញការដាក់ឱ្យដំណើរការយន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា | ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ យ៉ាងតិច ១៥ បានអនុវត្ត យន្តការទទួលព័ត៌មានត្រឡប់និងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវាសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យានៅឆ្នាំ២០២៣ | | √ | √ | √ | √ | - **ក្រសួងមុខងារសាធារណៈ និង លេខាធិការដ្ឋាន គ.ក.រ** |
| ២.៥.៣. រៀបចំបង្កើតនិងដាក់ឱ្យអនុវត្តមជ្ឈមណ្ឌលទូរស័ព្ទផ្តល់ព័ត៌មាននិងទទួលព័តមានត្រឡប់ស្តីពីសេវាសេវាសាធារណៈ | មជ្ឈមណ្ឌល ទូរស័ព្ទផ្តល់ព័ត៌មាននិងទទួលព័តមានត្រឡប់ស្តីពីសេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត | | √ | √ | | | - **ក្រសួងមុខងារសាធារណៈ និង លេខាធិការដ្ឋាន គ.ក.រ**<br>- **ក្រសួង ស្ថាប័ន**<br>- **រដ្ឋបាលថ្នាក់ក្រោមជាតិ** |
| **៣. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ** | | | | | | | |
| **៣.១ បន្តដំឡើងបៀវត្សជាប្រចាំឆ្នាំជូនមន្ត្រីរាជការ ស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងប្រាក់សោធន ជូននិវត្តន៍ជន និងអតីតយុទ្ធជន ដោយរៀបចំបើកផ្តល់តាមប្រព័ន្ធធនាគារក្នុង រយៈពេលពីរសប្តាហ៍ម្តង** | បៀវត្សមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំង ប្រាក់សោធនជូននិវត្តជន និងអតីតយុទ្ធជន ត្រូវបានដំឡើងជាប្រចាំឆ្នាំ | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងការពារជាតិ |
| ៣.១.១.រៀបចំកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែនីមួយៗជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីសាធារណៈផ្សេងៗទៀតតាមប្រព័ន្ធធនាគារ | សារាចរណែនាំស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងក្នុងខែ តាមប្រព័ន្ធធនាគារ ត្រូវបានដាក់ឱ្យអនុវត្ត | √ | | | | | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.១.២.សិក្សាលើប្រាក់បៀវត្សក្នុងវិស័យសាធារណៈ និងរៀបចំការព្យាករណ៍សម្រាប់ការដំឡើងប្រាក់បៀវត្ស ២០១៩ ២០២៣ | របាយការណ៍សិក្សា មូលដ្ឋានទិន្នន័យ និងការវាស់វែងទៅលើការអនុវត្តត្រូវបានដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច | √ | √ | | | | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ |
| ៣.១.៣. រៀបចំកែសម្រួលនិងដំឡើងបៀវត្សជូនមន្ត្រីសាធារណៈតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល | អនុក្រឹត្យស្តីពីការកែសម្រួលនិងដំឡើងបៀវត្សជូនមន្ត្រីសាធារណៈត្រូវបានដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ |
| **៣.២. ធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងចែក រំលែកបច្ចេកទេស តាមរយៈយន្តការវិមជ្ឈការ និងវិសហមជ្ឈការ ដល់អង្គភាពរដ្ឋបាលគ្រប់កម្រិតក្រោម ឱវាទក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ និងរដ្ឋបាល ថ្នាក់ក្រោមជាតិ ដើម្បីទទួលបានស្វ័យភាព សមស្រប ទាំងក្នុងការសម្រេចចិត្ត ការគ្រប់គ្រង និងការចាត់ចែងធនធានមនុស្សនិងហិរញ្ញវត្ថុ ទន្ទឹមនឹងការកំណត់ឱ្យបានច្បាស់លាស់នូវគណនេយ្យភាព និងការទទួលខុសត្រូវរបស់អង្គភាពសាធារណៈនិងមន្ត្រីសាធារណៈ** | ការធ្វើប្រតិភូកម្មអំណាច ការផ្ទេរមុខងារ ការផ្ទេរធនធាន និងចែករំលែកបច្ចេកទេសដល់ អង្គភាពរដ្ឋបាលគ្រប់កម្រិត ក្រោមឱវាទក្រសួង ស្ថាប័ន គ្រឹះស្ថាន សាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានលើកកម្ពស់ក្នុងការអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន NCDD<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន PFM<br>- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.២.១.សិក្សា និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ | លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ ដាក់ឱ្យអនុវត្ត និងពង្រឹង | √ | √ | √ | √ | √ | - ក្រសួងមហាផ្ទៃ និង លេខាធិការដ្ឋាន NCDD<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន PFM<br>- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.២.២ រៀបចំឯកសារគោលការណ៍ណែនាំសម្រាប់ ការពង្រាយមន្ត្រីរាជការ | ឯកសារគោលការណ៍ណែនាំស្តីពីការពង្រាយមន្ត្រីរាជការ ត្រូវបានរៀបចំឡើង | | √ | √ | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.៣.៣.ដាក់ឱ្យអនុវត្តឯកសារគោលការណ៍ណែនាំសម្រាប់ ការពង្រាយមន្ត្រីរាជការ ក្នុងវិស័យអប់រំ និងសុខាភិបាល | ឯកសារគោលការណ៍ណែនាំស្តីពីការពង្រាយមន្ត្រីរាជការ(អប់រំ និងសុខាភិបាល) ត្រូវបានកែលម្អួល និងដាក់ឱ្យអនុវត្ត | | | | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR<br>- ក្រសួងអប់រំ និងសុខាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **៣.៣ ជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈ** | **គ្រប់ក្រសួង ស្ថាប័ន អនុវត្តគំនិតប្រកបដោយនវានុវត្តន៍ និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាគាំទ្រដល់ការផ្តល់សេវាសាធារណៈ** | | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣.១.រៀបចំនិងដាក់ឱ្យអនុវត្តមូលនិធិនវានុវត្តន៍ដើម្បីលើកកម្ពស់ការច្នៃប្រឌិតក្នុងការកែលម្អគុណភាពសេវាសាធារណៈ ជូនប្រជាជន | បទដ្ឋានគតិយុត្តិស្តីពីការដាក់ឱ្យដំណើរការមូលនិធិនវានុវត្តន៍ត្រូវបានអនុម័តនិងផ្សព្វផ្សាយអនុវត្ត | | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣.២. រៀបចំនិងដាក់ឱ្យដំណើរការការវាយតម្លៃនិងទទួលស្គាល់ក្រុង ស្រុក ខណ្ឌគំរូ | បទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃនិងទទួលស្គាល់ក្រុង ស្រុក ខណ្ឌគំរូ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣.៣.បន្តនិងពង្រីកការអនុវត្តការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំនិងវិស័យសុខាភិបាល | អង្គភាពផ្តល់សេវាសាធារណៈនៅថ្នាក់មូលដ្ឋានរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងសុខាភិបាលត្រូវបានវាយតម្លៃនិងទទួលស្គាល់អំពីស្នាដៃនៃការផ្តល់សេវាប្រកបដោយគុណភាពជូនប្រជាជន | √ | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣.៤.ជំរុញចលនាអនុវត្តការវាយតម្លៃនិងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូនៅតាមក្រសួងស្ថាប័ន ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ | អង្គភាពផ្តល់សេវាសាធារណៈឆ្នើមនៅតាមក្រសួង ស្ថាប័ន ត្រូវបានវាយតម្លៃនិងលើកទឹកចិត្តក្នុងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាពជូនប្រជាពលរដ្ឋ | √ | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ៣.៣.៥.ជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យាដើម្បីកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ | សេវាសាធារណៈរបស់ក្រសួង ស្ថាប័ន យ៉ាងតិច ១២០ ថ្មីថែមទៀត ត្រូវបានផ្តល់ក្នុងទម្រង់ជាសេវាឌីជីថល | | √ | √ | √ | √ | - គណៈកម្មាការវាយតម្លៃអង្គភាពផ្តល់សេវាសាធារណៈថ្នាក់ជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| **៣.៤ ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដោយប្រើប្រាស់សូចនាករសមិទ្ធកម្មគន្លឹះ ពិសេសសម្រាប់មន្ត្រីក្នុងកម្រិតដឹកនាំនិងគ្រប់គ្រងស្ថាប័នសាធារណៈ** | ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និង ប្រព័ន្ធលើកទឹកចិត្តត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.៤.១.រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | បទដ្ឋានគតិយុត្ត និងឯកសារណែនាំអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR<br>- ក្រសួង ស្ថាប័ន |
| ៣.៤.២.រៀបចំកែសម្រួល និងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | បទដ្ឋានគតិយុត្ត និងឯកសារនៃនាំអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានកែលម្អនិងដាក់ឱ្យអនុវត្ត | √ | √ | | | | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន PFM<br>- ក្រសួងមុខងារសាធារណៈ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី |
| **៣.៥ ដាក់ឱ្យអនុវត្តយន្តការតាមដាន និងវាយតម្លៃ ដើម្បីជំរុញការអនុវត្តកែលម្អវិធានការតម្រង់ទិស យុទ្ធសាស្ត្រ និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរក្រសួង សម្រាប់ការកសាង រៀបចំ និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល** | - ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានរៀបចំ និង ដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.៥.១.រៀបចំនិងដាក់ឱ្យអនុវត្ត ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ | ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | | | | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.៥.២.ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារកែទម្រង់អន្តរវិស័យ | ផែនការសកម្មភាពរួម ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR |
| ៣.៥.៣.ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ដើម្បីគាំទ្រដល់ការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ | ធនធាននិងកិច្ចសហប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ត្រូវបានកៀរគរ និងបង្កើន | √ | √ | √ | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន PAR<br>- លេខាធិការដ្ឋាន NCDD, PFM, កំណែទម្រង់ប្រព័ន្ធច្បាប់និងយុត្តិធម៌ |
| **៣.៦ ពង្រឹងយន្តការចែករំលែកនិងការផ្លាស់ប្តូរព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេសដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងនិងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់សេវាសាធារណៈនៅក្នុងការវិវត្តដ៏ឆាប់រហ័សនៃបរិការណ៍ជាតិ និងអន្តរជាតិ** | បទដ្ឋានគតិយុត្ត និងយន្តការសម្រាប់សម្រួលដល់ការចែករំលែកព័ត៌មានក្នុងការលើកកម្ពស់ការចូលរួមនិងប្រសិទ្ធភាពនៃការបំពេញការងាររបស់រដ្ឋបាលសាធារណៈ ត្រូវបានអនុវត្ត | | √ | √ | √ | √ | - **ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងផែនការ**<br>- **ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ** |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.៦.១.រៀបចំនិងដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្តស្តីពីការចូលរួមរបស់ប្រជាជនក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ | បទដ្ឋានគតិយុត្តិស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនៃការផ្តល់សេវាសាធារណៈ ត្រូវបានរៀបចំនិងផ្សព្វផ្សាយអនុវត្ត | | | | √ | √ | - ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ<br>- ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ៣.៦.២.រៀបចំបង្កើតនិងដាក់ឱ្យអនុវត្តបទដ្ឋានគតិយុត្តស្តីពីការបង្កើតនិងអនុវត្តយន្តការចែករំលែកព័ត៌មានក្នុងរដ្ឋបាលសាធារណៈនៅគ្រប់កម្រិតនៅទូទាំងប្រទេស | បទដ្ឋានគតិយុត្តស្តីពីការបង្កើតនិងអនុវត្តយន្តការ ចែករំលែកព័ត៌មានក្នុងរដ្ឋបាលសាធារណៈត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត | √ | √ | | | | - ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងផែនការ<br>- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |
| ៣.៦.៣. សិក្សា និងរៀបចំបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងព័ត៌មាននៃស្ថាប័នសាធារណៈ ដើម្បីប្រមូលគ្រប់គ្រងនិងសម្រួលដល់ការចែករំលែកនិងប្រើប្រាស់ព័ត៌មាន/ទិន្នន័យក្នុងរដ្ឋបាលសាធារណៈ ត្រូវបានអនុវត្ត | ការសិក្សាលើការបង្កើតមជ្ឈមណ្ឌល គ្រប់គ្រងព័ត៌មាននៃស្ថាប័នសាធារណៈ ត្រូវបានបញ្ចប់និងដាក់ចេញជាអនុសាសន៍និងជម្រើសក្នុងការអនុវត្ត | √ | √ | | | | - ក្រសួងមហាផ្ទៃ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍<br>- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ក.រ |

| ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំអនុវត្ត | | | | | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|---|
| | | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ | ២០២៧ | |
| **គោលដៅ (ដំណាក់កាលទី២ ២០២៣-២០២៧) : ការអនុវត្តនិងការត្រួតពិនិត្យ វាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែក លើសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ** | | | | | | | |
| **១.ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្ត និងមិនទាន់អនុវត្តបានពេញ លេញក្នុងដំណាក់កាលទី១** | | | | | | | |
| ១.១.បញ្ចប់ការរៀបចំអង្គមន្ត្រីរាជការស៊ីវិលក្នុងមុខងារសាធារណៈ | អង្គវិជ្ជាជីវៈត្រូវបានបញ្ចប់និងដាក់ឱ្យ អនុវត្ត | √ | √ | | | | |
| ១.២.រៀបចំកែសម្រួលនិងដាក់ឱ្យអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការគ្រប់គ្រងធនធានមនុស្សតាមបែបវិមជ្ឈការ | ការធ្វើប្រតិភូកម្មមុខងារ សិទ្ធអំណាចនិងធន ធានទៅថ្នាក់ក្រោមជាតិត្រូវបានពង្រឹកជាលំដាប់ | √ | √ | √ | √ | √ | |
| ១.៣.ត្រួតពិនិត្យឡើងវិញនៃការគ្រប់គ្រងក្នុងការផ្តល់ប្រាក់ ឧបត្ថម្ភ សម្រាប់អង្គភាពផ្តល់សេវាសាធារណៈ | អង្គភាពដែលទទួលបានកម្រៃសេវា | √ | | √ | | √ | |
| ១.៤. បន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ តាមរយៈការប្រើប្រាស់នូវបច្ចេកវិទ្យាព័ត៌មានវិទ្យា និងនវានុវត្តន៍ | ការផ្តល់សេវាសាធារណៈត្រូវបានកែលម្អ | √ | √ | √ | √ | √ | |
| **២.បន្តអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម** | | | | | | | |
| ២.១.លើកកម្ពស់ការផ្តល់សេវាសាធារណៈតាមចង្កោមសេវា សាធារណៈថ្មីៗ | ចង្កោមសេវាសាធារណៈថ្មីក្នុងការផ្តល់សេវាសា ធារណៈតាមរយៈច្រកចេញចូលតែមួយ ទីភ្នាក់ ងារប្រតិបត្តិការពិសេស និងតាមគំរូម៉ូឌែលថ្មីៗ ត្រូវបានដាក់ចេញ | √ | √ | √ | √ | √ | |
| ២.២.កែសម្រួលនិងដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តសម្រាប់ មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | ប្រព័ន្ធនៃការលើកទឹកចិត្តសម្រាប់អង្គភាពនិង មន្ត្រីរាជការស៊ីវិលត្រូវបានដាក់ឱ្យអនុវត្ត | √ | | | | | |
| ២.៣.ដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មចំនួន១០ ក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច និងអង្គភាពច្រកចេញចូលតែមួយ ទីភ្នាក់ងារប្រតិបត្តិការពិសេស | មន្ត្រីនៅតាមក្រសួង ស្ថាប័នដែលទទួលបានការ លើកទឹកចិត្ត(ប្រាក់ឧបត្ថម្ភ) ត្រូវបានដាក់ឱ្យ អនុវត្តនូវប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | √ | √ | √ | √ | √ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.ការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | | | | | | | |
| ៣.១.រៀបចំនិងឱ្យអនុវត្តនូវការផ្ដល់ព័ត៌មានត្រឡប់តាមប្រព័ន្ធអេឡិត្រូនិក | ក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យ សង្គមកិច្ចនិងសេដ្ឋកិច្ច ក្នុងការផ្ដល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តនូវការផ្ដល់ព័ត៌មានត្រឡប់តាមប្រព័ន្ធអេឡិចត្រូនិក | √ | √ | √ | √ | √ | |
| ៣.២.ត្រួតពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធក្រសួងស្ថាប័នពាក់ព័ន្ធវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច | ក្រសួង ស្ថាប័នចំនួន១០ ដែលពាក់ព័ន្ធនឹងសេវា ត្រូវបានកែលម្អរចនាសម្ព័ន្ធ | √ | √ | √ | √ | √ | |
| ៣.៣.កែលម្អឡើងវិញប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស | ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សត្រូវបានដាក់ឱ្យអនុវត្តជាជម្រើស | √ | √ | √ | √ | √ | |

| ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំអនុវត្ត | | | | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|
| | | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | |
| **គោលដៅ (ដំណាក់កាលទី៣៖ ២០២៧-២០៣០) : គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ** | | | | | | |
| ១.ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្ត និងមិនទាន់អនុវត្តបានពេញលេញក្នុងដំណាក់កាលទី២ | | | | | | |
| ២.សេវាសាធារណៈប្រកបដោយឧត្តមភាព | | | | | | |
| ៣.តាមដានត្រួតពិនិត្យនិងវាយតម្លៃលើគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣.ការត្រួតពិនិត្យនិងវាយតម្លៃប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម | | | | | | | |
| ៣.១.រៀបចំនិងឱ្យអនុវត្តនូវការផ្ដល់ព័ត៌មានត្រឡប់តាមប្រព័ន្ធអេឡិត្រូនិក | ក្រសួង ស្ថាប័នពាក់ព័ន្ធវិស័យ សង្គមកិច្ចនិងសេដ្ឋកិច្ច ក្នុងការផ្ដល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្តនូវការផ្ដល់ព័ត៌មានត្រឡប់តាមប្រព័ន្ធអេឡិចត្រូនិក | √ | √ | √ | √ | √ | |
| ៣.២.ត្រួតពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធក្រសួងស្ថាប័នពាក់ព័ន្ធវិស័យសង្គមកិច្ចនិងសេដ្ឋកិច្ច | ក្រសួង ស្ថាប័នចំនួន១០ ដែលពាក់ព័ន្ធនឹងសេវា ត្រូវបានកែលម្អរចនាសម្ព័ន្ធ | √ | √ | √ | √ | √ | |
| ៣.៣.កែលម្អឡើងវិញប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស | ប្រព័ន្ធគ្រប់គ្រងធនធានមនុស្សត្រូវបានដាក់ឱ្យអនុវត្តជាជម្រើស | √ | √ | √ | √ | √ | |

| ចង្កោមសកម្មភាព/សកម្មភាព | សូចនាករសមិទ្ធកម្ម | ឆ្នាំអនុវត្ត | | | | ស្ថាប័នទទួលបន្ទុក |
|---|---|---|---|---|---|---|
| | | ២០២៧ | ២០២៨ | ២០២៩ | ២០៣០ | |
| គោលដៅ (ដំណាក់កាលទី៣៖ ២០២៧-២០៣០) : គណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ | | | | | | |
| ១.ការបន្តអនុវត្តសកម្មភាពដែលបានអនុវត្ត និងមិនទាន់អនុវត្តបានពេញលេញក្នុងដំណាក់កាលទី២ | | | | | | |
| ២.សេវាសាធារណៈប្រកបដោយឧត្តមភាព | | | | | | |
| ៣.តាមដានត្រួតពិនិត្យនិងវាយតម្លៃលើគណនេយ្យភាពសមិទ្ធកម្មចំពោះសេវាសាធារណៈ | | | | | | |

ក្រសួងមុខងារសាធារណៈ
អគ្គនាយកដ្ឋាននគោលនយោបាយមុខងារសាធារណៈ
លេខាធិការដ្ឋាន គ.ក.រ
ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ៖ +៨៥៥-២៣-៨៦៦៥០១
គេហទំព័រ៖ http://www.mcs.gov.kh
បណ្តាញសង្គម៖ http://www.facebook.com/CivilServiceCambodia